# ទេវទូតសូត្រ



## វគ្គវិសុទ្ធិមគ្គ


រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ ភួង~សុវណ្ណ



ពុទ្ធសករាជ ២៥៥៦

# ទេវទូតសូត្រ



## វត្តវិសុទ្ធិមគ្គ

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ ភួង~សុវណ្ណ

ពុទ្ធសករាជ ២៥៥៦

-សៀវភៅ **ទេវទូតសូត្រ**

-រៀបរៀងដោយភិក្ខុ **សុវណ្ណជោតោ  តួច-សុវណ្ណ**

ជាអាចារ្យបង្រៀនព្រះវិន័យ ឧត្តមសិក្សាវត្តនិគ្រោធវ័ន

-ទីកន្លែងធ្វើ **វត្តនិគ្រោធវ័ន  រាជធានីភ្នំពេញ**

និង **វត្តវិសុទ្ធិមគ្គ  (ភិនវិន្ធារាម)**

**-អ្នកជួយពិនិត្យ**   ធម្មាចារ្យ **សុមេធបណ្ឌិតោ ស៊ិន  ផល្លា**

ធម្មាចារ្យ  **វិនយធរោ  គុន  ប៊ុនសាយ**

ធម្មាចារ្យ **មង្គលបាលិតោ  នី  សុភក្តិ**

-ធម្មទានដោយ :

-ឧបាសិកា ទៀង សុធម្មរិទ្ធ   -ឧបាសិកា តាំង អ៊ៀងស៊ុយ

-លោក ជាមហួរ ហុង + អ្នកស្រី សុខ គាង ព្រមទាំងកូនចៅ

-ឧបាសិកា ហេ ងិចឆៃ ព្រមទាំងបុត្រ

-សាវិកា ជឹប ស្រីពេជ្រ

-ឧបាសក ស៊ីវ សៅ + ឧបាសិកា ស្រ៊ាង វួចលាង

-ព្រមទាំងពុទ្ធបរិស័ទទូទៅ

-ពុទ្ធសករាជ  ២៥៥៦

# អារម្ភកថា

ព្រះមានព្រះភាគ ជាព្រះតថាគត ទ្រង់មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងលើសចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញពួកសត្វលោកដែលច្យុត ដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួន ។ សត្វទាំងឡាយណា ប្រកបដោយកាយសុចរិត ។ល។ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ចំណែកពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។ ពួកនិរយបាល ចាប់បុរសនោះ ត្រង់ដើមដៃផ្សេងៗ នាំយកទៅថ្វាយព្រះយមរាជ រួចក្រាបទូលថា "បពិត្រព្រះឧបបត្តិទេព បុរសនេះ ជាអ្នកមិនគោរពមាតាបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនកោតក្រែងក្នុងត្រកូលរៀមច្បងទេ សូម

ទ្រង់ដាក់អាជ្ញាដល់បុរសនេះចុះ” ។ ទើបព្រះយមរាជ សាកសួរ ដេញដោល សួរឈ្ងេចឈ្ងី នូវទេវទូតទី ១ រហូតដល់ទី ៥ នឹង បុរសនោះ ។ អ្នកណាមានបាបកម្មតិចតួច ចួនកាលរលឹកបាន តាមធម្មតារបស់ខ្លួនឯង ចួនកាលទាល់តែគេរំលឹក ក៏រលឹកបាន ។ តែកាលរលឹកតាមធម្មតារបស់ខ្លួនឯងមិនបានទេ ទើបសួរទេវទូត ទាំង ៥ ។ ក្នុងទេវទូតទាំង ៥ នោះ អ្នកខ្លះរលឹកបានដោយ ទេវទូតទី ១ ។ អ្នកខ្លះរលឹកបានដោយទេវទូតទី ២ ជាដើម ។ ចំណែកអ្នកណា រមែងរលឹកមិនបានដោយទេវទូតទាំង ៥ ស្ដេច យមរាជ ឲ្យអ្នកនោះរលឹកបានឯង ។ សត្វនរក កាលរលឹកបាន នូវទេវទូតណាមួយ ដែលខ្លួនធ្លាប់ពិចារណា ឬរលឹកដល់កុសល-កម្មតាមធម្មតាដែលខ្លួនធ្លាប់ធ្វើពីមុន ទើបចុតិពីកំណើតនរក កើត ក្នុងទេវលោកបាន ។ ក៏ប៉ុន្តែថា កាលរលឹកតាមធម្មតារបស់ខ្លួន មិនបាន, សូម្បីស្ដេចយមរាជ ត្រួតមើល ក៏មិនឃើញកុសលកម្ម ទ្រង់ត្រិះរិះថា សត្វនេះនឹងសោយទុក្ខធំ ទើបទ្រង់នៅស្ងៀម ។

ព្រោះហេតុដូច្នេះ យើងត្រូវសិក្សាឲ្យយល់ពីទេវទូតទាំង ៥ នេះ ហើយត្រូវគិតពិចារណា ឲ្យកើតសេចក្ដីសង្វេគ រស់នៅ

ដោយបញ្ញា ដោយសេចក្ដីមិនប្រមាទ ។ គប្បីពិចារណាយ៉ាងណា ? ការប្រៀបធៀប ពិចារណា មាននៅក្នុងសៀវភៅនេះ ។

សេចក្ដីសង្ខេបថា ដូចជាយើងឃើញ **ក្មេងខ្ចី អ្នកចាស់ អ្នកឈឺ កម្មករណ៍ ឬអ្នកជាក់ទោស និងអ្នកស្លាប់**, យើងត្រូវពិចារណា ប្រៀបធៀបមកខ្លួនឯង គឺ **ក្មេងខ្ចី**ជាដើមនោះ សូម្បីមិនបានបញ្ចេញវាចាប្រាប់យើងទេ តែក៏ដូចជាពោលប្រាប់ ដាស់តឿនថា "សូម្បីលោកក៏មានយ៉ាងនេះ ជាធម្មតា" ។ **ក្មេងខ្ចី** ជាដើមនោះ រមែងពោលដោយសេចក្ដីយ៉ាងនេះថា "អ្នកដ៏ចម្រើន ចូរមើលយើង សូម្បីយើងក៏មានដៃនិងជើង ដូចជាពួកលោកដែរ តែយើងដេកនៅក្នុងមូត្រនិងលាមករបស់ខ្លួន មិនអាចដើម្បីនឹងក្រោកឡើងងូតទឹកតាមធម្មតារបស់ខ្លួនបាន យើងជាអ្នកមានកាយស្មោកគ្រោក ហើយមិនអាចដើម្បីនឹងប្រាប់ថា ងូតទឹកឲ្យយើង យើងប្រាកដដូច្នេះ ព្រោះមិនផុតពីការកើត, មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីលោកទាំងឡាយក៏មិនផុតពីការកើត ការកើតនឹងមកដល់សូម្បីលោកទាំងឡាយដូចយើងដែរ លោកចូរធ្វើសេចក្ដីល្អទុក តាំងអំពីមុនកើតនោះ" ដោយប្រការដូច្នេះ ។

*សូម្បីក្នុងសត្វចាស់ជរា* រមែងពោលដោយសេចក្ដីយ៉ាងនេះថា "អ្នកដ៏ចម្រើន ពួកលោកចូរមើល សូម្បីយើងក៏ធ្លាប់ជាកំលោះ បរិបូរណ៍ដោយកម្លាំងជើង កម្លាំងដៃ និងរហ័សរហួនដូចលោកដែរ ការដល់ព្រមដោយកម្លាំង និងសេចក្ដីរហ័សរហួនទាំងនោះ របស់យើងនោះ សូន្យអស់ទៅហើយ សូម្បីដៃនិងជើងរបស់យើងមាន ក៏ធ្វើកិច្ចដោយដៃនិងជើងមិនបាន, យើងប្រាកដដូចនេះ ព្រោះមិនផុតពីជរា, មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីលោកទាំងឡាយក៏មិនរួចផុតទៅពីជរាដែរ ភាពជរានឹងមកដល់លោកទាំងឡាយដូចយើងដែរ លោកទាំងឡាយ ចូរធ្វើសេចក្ដីល្អទុកមុនអំពីការជរានោះនឹងមកដល់" ដោយប្រការដូច្នេះ ។

*សូម្បីក្នុងសត្វអ្នកឈឺ* រមែងពោលដោយសេចក្ដីយ៉ាងនេះថា "អ្នកដ៏ចម្រើនពួកលោកចូរមើល សូម្បីយើងក៏ជាអ្នកមិនមានរោគដូចលោក យើងនោះឥឡូវនេះ ត្រូវព្យាធិគ្របសង្កត់ដេកត្រាំនៅក្នុងទឹកមូត្រ និងលាមករបស់ខ្លួន មិនអាចដើម្បីនឹងក្រោកឡើងបាន សូម្បីដៃនិងជើងរបស់យើងមាន ធ្វើកិច្ចដោយដៃនិងជើងមិនបានឡើយ យើងប្រាកដដូចនោះ ព្រោះមិន

ផុតពីព្យាធិ មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីលោកទាំងឡាយ ក៏មិនរួចផុតពីព្យាធិ ។ ព្យាធិនឹងមកដល់យើងយ៉ាងណា ព្យាធិនឹងមកដល់លោកទាំងឡាយយ៉ាងនោះ, លោកចូរធ្វើសេចក្ដីល្អទុកមុនអំពីព្យាធិនឹងមកដល់" ដោយប្រការដូច្នេះ ។

សូម្បីក្នុង**កម្មករណ៍ ៣២** រមែងពោលដោយសេចក្ដីយ៉ាងនេះថា "ពួកយើងកាលកើត រមែងមិនកើតក្នុងដើមឈើ ឬក្នុងថ្មទេ គឺរមែងកើតក្នុងសរីរៈរបស់បុគ្គលដូចជាលោក ដោយប្រការដូច្នេះ លោកចូរធ្វើសេចក្ដីល្អទុកមុនយើងកើត" ។

សូម្បី**អ្នកដាក់ទោស** រមែងពោលដោយសេចក្ដីយ៉ាងនេះថា "ពួកយើងកាលនឹងដាក់កម្មករណ៍ ៣២ យ៉ាង មិនបានដាក់ក្នុងដើមឈើជាដើមទេ រមែងដាក់ក្នុងសត្វដូចពួកលោកនុ៎ះឯង ។ ដោយប្រការដូច្នេះ ពួកលោកចូរធ្វើសេចក្ដីល្អមុនដែលយើងនឹងដាក់ទោស" ។

ក្នុង**សត្វអ្នកស្លាប់ហើយ** រមែងពោលដោយសេចក្ដីយ៉ាងនេះថា "អ្នកដ៏ចម្រើន ពួកលោកចូរមើលយើង ដែលគេទុកចោលក្នុងព្រៃជាទីចោលសាកសព ដល់នូវភាពកំពុងហើមប៉ោងជាដើម

យើងប្រាកដដូច្នេះ ព្រោះមិនផុតពីសេចក្ដីស្លាប់ តែមិនមែនយើងប៉ុណ្ណោះទេ សូម្បីពួកលោកក៏មិនផុតពីសេចក្ដីស្លាប់ដូចគ្នាដែរ សេចក្ដីស្លាប់នឹងមកដល់លោកទាំងឡាយដូចយើងដែរ ពួកលោកចូរធ្វើសេចក្ដីល្អមុនសេចក្ដីស្លាប់នោះនឹងមកដល់" ដូច្នេះ ។

ក្នុងសេចក្ដីនេះ ពិតជាសំខាន់ណាស់ ដែលយើងត្រូវតែចេះគិតពិចារណា ដើម្បីការរស់នៅមិនប្រមាទក្នុងកុសលធម៌ ។

ក្នុងអដ្ឋកថា ថា "ក៏ភិក្ខុកំលោះមួយរូប កាលរៀនព្រះ-សូត្រនេះ ពោលថា លោកម្ចាស់ដ៏ចម្រើន កាលសត្វនរកសោយទុក្ខប៉ុណ្ណោះហើយ នាយនិរយបាលនៅបោះគេទៅក្នុងមហានរកទៀតឬ ។ ភិក្ខុពោលថា លោកម្ចាស់ដ៏ចម្រើន ឧទ្ទេសចូរលើកទុក លោកម្ចាស់ចូរប្រាប់កម្មដ្ឋានដល់ខ្ញុំ ឲ្យព្រះថេរៈប្រាប់កម្មដ្ឋានហើយ ជាព្រះសោតាបន្ន អាស្រ័យរៀនឧទ្ទេស ។ ជនសូម្បីពួកដទៃរៀនឧទ្ទេសក្នុងបទេសនេះ សម្រេចអរហត្ត មិនមានចំនួន (រាប់ចំនួនមិនបាន) ។ ក៏ព្រះសូត្រនេះ (ទេវទូតសូត្រ) ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនវៀរឡើយ" ។

ក្នុងសៀវភៅនេះ ខ្ញុំបានសរសេរពីទេវទូតសូត្រ ទាំងស្រុង

និងអដ្ឋកថា ទើបដាក់ឈ្មោះថា **ទេវទូតសូត្រ** និងសរសេរពីប្រែតខ្លះនៅខាងចុង ក៏ដើម្បីឲ្យពុទ្ធបរិស័ទសិក្សា យល់ពីកម្មនិងផលរបស់កម្ម រឿងនេះមានពិត សូមពិចារណាមើល តាមន័យអដ្ឋកថាចុះ ។ ព្រោះហេតុនោះ គួរតែភ័យខ្លាច តក់ស្លុតនិងគួរតែនឿយណាយ គួរជិនឆ្អន់ ក្នុងសង្ខារទាំងពួង ។

ដោយមហាកុសលចេតនាណា ដែលខ្ញុំមានសេចក្ដីជ្រះថ្លាក្នុងព្រះសទ្ធម្ម ហើយរចនានេះ សូមឧទ្ទិសសៀវភៅនេះជាសក្ការៈបូជា ថ្វាយចំពោះព្រះរតនត្រៃ, សូមព្រះសទ្ធម្មរបស់ព្រះសម្ពុទ្ធឋិតនៅអស់កាលយូរ ។ ដោយអានុភាពនៃបុណ្យទាំងពួងនេះសូមពួកញាតិនិងសព្វសត្វនិករ មួយអន្លើដោយពុទ្ធបរិស័ទទាំងឡាយ ចូរបានសេចក្ដីសុខ ចូរជាអ្នកសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ ។ សូមបានជាឧបនិស្ស័យនៃការត្រាស់ដឹងនូវធម៌ ដល់ព្រមដោយបដិសម្ភិទា ក្នុងសាសនារបស់ព្រះមានព្រះភាគ ក្នុងកាលជាអនាគត ។ សូមអនុមោទនា !!!

វត្តវិសុទ្ធិមគ្គ ថ្ងៃ ២ កើត ខែអស្សុជ ព.ស.២៥៥៦

**ភិក្ខុ សុវណ្ណជោតោ គួង-សុវណ្ណ**

# ច្បាប់ធម្មជាតិ

១-កើតចាស់ឈឺស្លាប់ជាច្បាប់ធម្មជាតិ ពិតមិនឃ្លៀងឃ្លាតទៅជាដទៃ
ព្រោះហេតុដូច្នោះយើងត្រូវលកលៃ រវៀសរវៃប្រព្រឹត្តធម៌អាថ៌ ។
២-ឱជីវិតនេះតិចតួចពេកណាស់ អស់ទៅរហ័សមិនយូរឡើយណា
ព្រះអង្គបានត្រាស់ជាពុទ្ធដីកា ស្លាប់ចោលកាយាត្រាច់ទៅតាមកម្ម ។
៣-បុគ្គលធ្វើបាបតែងតែសោយទុក្ខ នៅលោកខាងមុខរាប់ម៉ឺនសែនឆ្នាំ
ស្រេកទឹកឃ្លានបាយភ្លើងឆេះប្រចាំ រងទុក្ខតាមកម្មមិនងាយរួចខ្លួន ។
៤-ឯអ្នកធ្វើល្អតែងបានសុខា តាមចិត្តប្រាថ្នាដឹងចុះមាសស្ងួន
នាំបាននិព្វានក្តីសុខមាំមួន នេះទើបរួចខ្លួនពីចាស់ឈឺស្លាប់ ។
៥-ហេតុនេះគួរតែខំប្រព្រឹត្តល្អ ទានសីលបវរធ្វើដោយប្រញាប់
ចម្រើនភាវនាទៅតាមលំដាប់ ឆ្ការគាស់កាយកាប់កិលេសតណ្ហា ។
៦-ចំណែកបព្វជិតត្រូវតែប្រឹងប្រែង សិក្សាកោតក្រែងក្នុងត្រៃសិក្ខា
សីលសមាធិព្រមទាំងបញ្ញា លើកវិបស្សនាត្រាស់ដឹងសច្ចៈ ។

វត្តវិសុទ្ធិមគ្គ ថ្ងៃ ០៣កើត ខែអស្សុជ ព.ស.២៥៥៦
ភិក្ខុ សុវណ្ណជោតោ ភ.ស.វ.

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

អារម្ភកថា ...... ...... ...... ...... ...... ...... ...... ...... ..... ក

សន្លឹកប្រាប់មាតិកា ...... ...... ...... ...... ...... ...... .... ឈ

**I.** ទេវទូតសូត្រ ...... ...... ...... ...... ...... ...... ...... ... ១

អដ្ឋកថាទេវទូតសូត្រ ...... ...... ...... ...... ...... ........ ២៥

ទេវទូត ទី១ ...... ...... ...... ...... ...... ...... ...... ... ២៩

ទេវទូត ទី២ ...... ...... ...... ...... ...... ...... ...... ... ៣០

ទេវទូត ទី៣ ...... ...... ...... ...... ...... ...... ...... ... ៣១

ទេវទូត ទី៤ ...... ...... ...... ...... ...... ...... ...... ... ៣២

ទេវទូត ទី៥ ...... ...... ...... ...... ...... ...... ...... ... ៣៣

អ្នកត្រូវសាកសួរទេវទូត ...... ...... ...... ...... ...... .... ៣៣

ការដាក់ខ្ញុំទោសក្នុងនរក ...... ...... ...... ...... ...... ..... ៤៥

**II.** អំពីប្រេតទាំងឡាយ

១-អដ្ឋិសង្ខលិក ...... ...... ...... ...... ...... ...... ...... ៤៨

២-មំសបេសិប្រេត ...... ...... ...... ...... ...... ...... .... ៥៩

៣-មំសបិណ្ឌប្រេត ...... ...... ...... ...... ...... ...... ... ៦០

៤-និច្ឆវីប្រេត ...... ...... ...... ...... ...... ...... ...... ... ៦០

៥-អសិលោមប្រេត ...... ...... ...... ...... ...... ...... ... ៦១

៦-សត្តិលោមប្រេត ...... ...... ...... ...... ...... ...... ... ៦២

៧-ឧសុលោមប្រេត ...... ...... ...... ...... ...... ...... ... ៦៣

៨-សូចិលោមប្រេត ...... ...... ...... ...... ...... ...... ... ៦៤

៩-សូចិលោមបុរស ...... ...... ...... ...... ...... ...... .... ៦៥

១០-កុម្ភណ្ឌប្រេត ...... ...... ...... ...... ...... ...... ..... ៦៦

១១-រឿងបរទារិកប្រេត ...... ...... ...... ...... ...... .... ៦៧

១២-រឿងព្រាហ្មណ៍កំណាច ...... ...... ...... ...... ...... .. ៦៨

១៣-រឿងនិច្ឆវិប្រេត ...... ...... ...... ...... ...... ...... .. ៦៩

១៤-រឿងមង្គុឡីស្រីប្រេត ...... ...... ...... ...... ...... .. ៧០

១៥-រឿងឱកិលិនីស្រីប្រេត ...... ...... ...... ...... ...... .. ៧១

១៦-រឿងចោរឃាតប្រេត ...... ...... ...... ...... ...... ... ៧៣

១៧-រឿងភិក្ខុប្រេតជាដើម ...... ...... ...... ...... ...... .. ៧៣

១៨-រឿងសាមណេរីប្រេត ...... ...... ...... ...... ...... ... ៧៥

**III.** អត្ថបទកំណាព្យ

១-ទេវទូត ...... ...... ...... ...... ...... ...... ...... ..... ៧៧

២-ឃ្លាតទុក្ខជួបសុខ ...... ...... ...... ...... ...... ...... .. ៧៩

៣-ត្រូវប្រព្រឹត្តធម៌ ...... ...... ...... ...... ...... ...... .... ៨០

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

# I. ទេវទូតសូត្រ

*ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។*

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មានផ្ទះពីរ ប្រកបដោយទ្វារ ក្នុងផ្ទះនោះ មានបុរសភ្នែកភ្លឺម្នាក់ឈរចំកណ្តាល គប្បីមើលឃើញពួកមនុស្សដែលកំពុងចូលទៅកាន់ផ្ទះក្តី ចេញអំពីផ្ទះក្តី កំពុងសញ្ចរទៅមកក្តី កំពុងត្រាច់ទៅមកក្តី សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចតថាគត មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងលើសចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញពួកសត្វលោកដែល*

ច្យុត ដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក, ចំណែកសត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចី-សុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងមនុស្ស-លោក, អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះ-អរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតប្រេតវិស័យ ចំណែកសត្វទាំងនេះ ប្រកបដោយកាយ-

ទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ចំណែកពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។

"ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ ត្រង់ដើមដៃផ្សេងៗ នាំយកទៅថ្វាយព្រះយមរាជ រួចក្រាបទូលថា បពិត្រព្រះឧបបត្តិទេព បុរសនេះជាអ្នកមិនគោរពមាតាបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនកោតក្រែងក្នុងត្រកូលរៀមច្បងទេ សូមទ្រង់ដាក់អាជ្ញាដល់បុរសនេះចុះ" ។

ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសាកសួរដេញដោល សួរឈ្ងុចឈ្ងី នូវទេវទូតទី ១ នឹងបុរសនោះថា នែបុរសអ្នកឯងមិនបានឃើញទេវទូតទី ១ ដែលកើតប្រាកដ ក្នុងមនុស្ស-

លោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះ-មេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា ម្នាលបុរស អ្នកឯងមិនបានឃើញកូនខ្ចី កំពុងដេកផ្ងារ ដេកត្រាំក្នុងទឹកមូត្រ និងលាមករបស់ខ្លួន ក្នុងមនុស្សលោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ បានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរសអ្នកឯងនោះដឹងក្តីឡើងរហូតដល់ចាស់ តើមានគំនិតថា **“អាត្មាអញឯង មានជាតិជាធម្មតា មិនកន្លងនូវជាតិទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញ ធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត”** ដូច្នេះដែរឬទេ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ មិនអាច (នឹងគិតឃើញដូច្នោះ) បានឡើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ មានព្រះរាជឱង្ការពន្យល់បុរសនោះ យ៉ាងនេះថា ម្នាលបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនបានធ្វើ

អំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាល នឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ១ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្លេចឈ្លីនូវទេវទូតទី ២ ទៀតថា ម្នាលបុរស អ្នកឯងមិនបានឃើញទេវទូតទី ២ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស ចុះអ្នកឯង មិនបានឃើញស្ត្រី ឬបុរសដែលមានអាយុ

៨០ ឆ្នាំ ៩០ ឆ្នាំ ១០០ ឆ្នាំ ដែលចាស់គ្រាំគ្រាអំពីកំណើត មានឆ្អឹងជំនីរកោងដូចជាបង្កង់ផ្ទះ មានកាយកោង កាន់ឈើច្រត់ ដើរទៅញ័ររន្ធត់ ក្តៅអន្ទះសា មានវ័យជ្រុលហួសហើយ មានធ្មេញបាក់ មានសក់ស្កូវ មានក្បាលឆក មានក្បាលទំពែក មានស្បែកជ្រួញជ្រីវ មានខ្លួនសៅហ្មងដោយប្រជ្រុយក្នុងមនុស្សលោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះដឹងក្តីឡើងរហូតដល់ចាស់ តើមានគំនិតថា “**អាត្មាអញឯងមានសេចក្តីគ្រាំគ្រាជាធម្មតា មិនកន្លងនូវសេចក្តីគ្រាំគ្រាទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត**” ដូច្នេះដែរឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងគិតឃើញ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជក៏ត្រាស់ពន្យល់បុរសនោះយ៉ាងនេះថា ម្នាលបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯង

មិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯងមានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណ-ព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញ-ដោល សួរឈ្លេចឈ្លី នូវទេវទូតទី ២ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៣ ទៀតថា ម្នាលបុរសអ្នកឯងមិនបានឃើញនូវទេវទូតទី ៣ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិនបានឃើញនូវស្ត្រី ឬបុរស ដែលមានជម្ងឺ

ដល់នូវសេចក្តីលំបាក ឈឺធ្ងន់ កំពុងដេកត្រាំក្នុងទឹកមូត្រ និង លាមករបស់ខ្លួន លុះតែមានពួកជនដទៃគ្រាហ៍ ទើបក្រោករួច មានពួកជនដទៃគ្រាហ៍ទើបចូលមកបាន ក្នុងមនុស្សលោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ សួរ បុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តី ឡើងរហូតដល់ចាស់ តើមានគំនិតថា "**អាត្មាអញឯង មានជម្ងឺ ជាធម្មតា មិនកន្លងនូវជម្ងឺទៅបានឡើយ បើដូច្នោះ គួរតែអាត្មា-អញ ធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត**" ដូច្នេះ ដែរឬទេ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះ-មេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងគិតឃើញ)ទេ សូមទ្រង់ ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំង-ឡាយ ព្រះយមរាជត្រាស់ពន្យល់បុរសនោះយ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនបានធ្វើអំពើល្អ ដោយ កាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯងមានសេចក្តី ប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ

ដ្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោលសួរឈ្មេចឈ្ងី នូវទេវទូតទី ៣ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្មេចឈ្ងី នូវទេវទូតទី ៤ ទៀតថា នែបុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៤ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជ ត្រឡប់សួរបុរសនោះយ៉ាងនេះវិញថា នែបុរស ចុះអ្នកឯងបានឃើញនូវព្រះរាជាទាំងឡាយកាលចាប់ចោរដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយ

ផ្កាខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខ-មុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសំបកស័ង្ខខ្លះ ឲ្យធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហុខ្លះ ឲ្យធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើហត្ថប្បជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាពន្ទាត់ស្បែកពពែខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ឲ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬសន្ទូចខ្លះ ឲ្យធ្វើនូវកហា-បណកកម្ម គឺអំពើដែលគេធ្វើឲ្យខ្ទូចសរីរៈប្រមាណប៉ុនកហា-បណៈមួយៗ ខ្លះ ឲ្យធ្វើខារាបតិច្ឆកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ឲ្យធ្វើនូវបលីឃបវត្តិកកម្ម គឺអំពើដែលគេធ្វើ

ឲ្យដូចជាបន្ទិលជើងគុល ឬសសរគោលខ្លះ ឲ្យធ្វើនូវបលាល-
បីឋកកម្ម គឺអំពើដែលធ្វើឲ្យដូចជាកណ្ដាប់ចំបើងខ្លះ ឲ្យស្រោច
ប្រេងដែលក្ដៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្ដោតទាំង
រស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ដូច្នេះដែរឬទេ ? បុរសនោះ
ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបាន
ឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ សួរបុរសនោះ
យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្ដីឡើង រហូត
ដល់ចាស់ តើមានគំនិតថា "**បានឮថា អ្នកណា ធ្វើនូវបាបកម្ម
ទាំងឡាយ អ្នកនោះ គេនឹងធ្វើកម្មករណ៍ផ្សេងៗ យ៉ាងនេះវិញ
ក្នុងបច្ចុប្បន្ននេះឯង នឹងបាច់និយាយថ្វីក្នុងបរលោក បើដូច្នោះ
គួរតែអាត្មាអញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត**"
ដូច្នេះដែរឬទេ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់
ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងគិតឃើញ)ទេ សូមទ្រង់
ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំង
ឡាយ ព្រះយមរាជ ក៏ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា
នែបុរស ព្រោះតែសេចក្ដីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អ

ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯងមាន សេចក្តីប្រមាទយ៉ាងណា ពួកនិរយបាល នឹងធ្វើ(អ្នកឯង) យ៉ាង នោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនុ៎ះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែន បងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួក ញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯង នឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។

ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរដេញដោល សួរឈ្វេចឈ្វី នូវទេវទូតទី ៤នឹងបុរសនោះរួចហើយ ទើបសាក សួរដេញដោល សួរឈ្វេចឈ្វី នូវទេវទូតទី ៥ ទៀតថា នែ បុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៥ ដែលកើតប្រាកដ ក្នុងមនុស្សលោកទេឬ ? បុរសនោះក្រាបទូលយ៉ាងនេះថា សូម ទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុ ទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិនបានឃើញស្ត្រី ឬបុរសដែលស្លាប់អស់

មួយថ្ងៃ ឬស្លាប់អស់ពីរថ្ងៃ ឬក៏ស្លាប់អស់បីថ្ងៃ កំពុងហើមប៉ោង មានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ទេឬ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គឃើញ ។ ម្នាលកិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះយ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះដឹងក្តីឡើងរហូតដល់ចាស់ តើមានគំនិតថា **“អាត្មាអញឯង មានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត”** ដូច្នេះដែរឬទេ ? បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច (នឹងគិតឃើញ)ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលកិក្ខុទាំងឡាយ ព្រះយមរាជ ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯងមានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ (អ្នកឯង) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ

មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរដេញដោល សួរឈ្ងេចឈ្ងី នូវទេវទូតទី ៥ នឹងបុរសនោះរួចហើយ ក៏ទ្រង់នៅស្ងៀម ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ធ្វើនូវកម្មករណ៍ ឈ្មោះបញ្ចពិធពន្ធន៍ (ចំណងប្រាំប្រការ) ចំពោះបុរសនោះ គឺផ្តេក (បុរសនោះ) ហើយបោះដែកគោលដ៏ក្តៅត្រង់ដៃ (ខាងស្តាំ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងស្តាំ ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅ ចំកណ្តាលទ្រូង ១ បុរសនោះ ក៏រងទុក្ខ-វេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងទីនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ លុះពួកនិរយបាល ចាប់ផ្តេកបុរស

នោះរួចហើយ ទើបចាំងដោយដឹង ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះ-ក្រោមហើយច្រាសដោយកាំបិតព្រា ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុរសនោះនឹងរថ ហើយបរទៅបរមកលើប្រឹថពី ដែលភ្លើងកំពុងឆេះ ក្តៅសព្វ ភ្លឺប្រាលរន្ទាល សន្ធោ-សន្ធៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ប្រើបុរសនោះឲ្យឡើងភ្នំ ឲ្យចុះអំពីភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងក្តៅសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយទម្លាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ។ បុរសនោះ ក៏ឆេះនឹងកំសួលពពុះក្នុងខ្ទះទង់ដែងនោះ ។ កាលបុរសនោះ ឆេះនឹងកំសួលពពុះក្នុងខ្ទះទង់ដែងនោះ ជួនកាលអណ្តែតឡើងលើម្តង ជួនកាលលិចចុះក្រោមម្តង ជួនកាលអណ្តែតទៅទទឹងម្តង ។ បុរសនោះ រងទុក្ខ-វេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងខ្ទះទង់ដែងនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏បោះបុរសនោះ ទៅក្នុងមហានរក ។ ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោត

មានជ្រុងបួន មានទ្វារបួន បែងចែកដោយចំណែកៗ មានរបងដែកព័ទ្ធព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃផែនដីខាងក្រោមនៃមហានរកនោះ សុទ្ធតែដែក មានភ្លើងឆេះប្រាលរន្ទាល ផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗ កាល ។

ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង មានអណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងកើត ឆាបដល់ជញ្ជាំងខាងលិច ។ អណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងលិច ឆាបដល់ជញ្ជាំងខាងកើត ។ អណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងជើង ឆាបដល់ជញ្ជាំងខាងត្បូង ។ អណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងត្បូង ឆាបដល់ជញ្ជាំងខាងជើង ។ អណ្តាតភ្លើងឆេះឡើងអំពីខាងក្រោម ឆាបដល់ខាងលើ អណ្តាតភ្លើងឆេះឡើងអំពីខាងលើ ឆាបដល់ខាងក្រោម ។ បុរសនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុង

មហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ ។ បុរសនោះ ក៏ស្ទុះដ៏រហ័សទៅត្រង់ទ្វារនោះ ។ កាលដែលបុរសនោះ ស្ទុះទៅដោយសន្ទុះដ៏រហ័ស ភ្លើងដ៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះតាំងនៅ (ក្នុងទីនោះ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាល បិទទៅវិញ ។ បុរសនោះ រងទុក្ខវេទនាក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងលិចនៃអវីចិមហានរកនោះ ។បេ។ បើកទ្វារខាងជើង ។បេ។ បើកទ្វារខាងត្បូង ។

បុរសនោះ ក៏ស្ទុះដោយសន្ទុះដ៏រហ័ស ទៅត្រង់ទ្វារនោះ ។ កាលបុរសនោះស្ទុះទៅ ដោយសន្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះ ប្រាកដដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះតាំងនៅ(ក្នុងទីនោះ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាលបិទទៅវិញ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ ។ បុរសនោះ ក៏ស្ទុះទៅដោយសន្ទុះដ៏រហ័ស ទៅត្រង់ទ្វារនោះ ។ កាលបុរសនោះស្ទុះដោយសន្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះប្រាកដដូច្នោះឯង ។ បុរសនោះ ក៏ស្ទុះចេញទៅ

តាមទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ មានគូថនរក (នរកពេញ ហៀរដោយលាមក)ដ៏ធំ តាំងនៅបន្ទាប់គ្នានឹងមហានរកនោះឯង ។ បុរសនោះធ្លាក់ទៅក្នុងគូថនរកនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុង គូថនរកនោះសោត មានសត្វទាំងឡាយមាត់ស្រួចដូចម្ជុល កកេរ ស្បែកក្រៅ លុះកកេរស្បែកក្រៅហើយ កកេរស្បែកក្នុង លុះ កកេរស្បែកក្នុងហើយ កកេរសាច់ លុះកកេរសាច់ហើយ កកេរ សរសៃ លុះកកេរសរសៃហើយ កកេរឆ្អឹង លុះកកេរឆ្អឹងហើយ ទើបខាំស៊ីខួរក្នុងឆ្អឹង ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងគូថនរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ មានកុក្កុលនរក (នរកពេញហៀរ ដោយផេះក្តៅ)ដ៏ធំ តាំងនៅបន្ទាប់គ្នានឹងគូថនរកនោះឯង ។ បុរស នោះ ធ្លាក់ទៅក្នុងកុក្កុលនរកនោះ ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងកុក្កុលនរកនោះ បើបាបកម្មមិនទាន់អស់ ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ មានព្រៃរកាដ៏ធំ ខ្ពស់ត្រដួចឡើង

មួយយោជន៍ មានបន្ទា ១៦ ធ្នាប់ ភ្លើងឆេះក្តៅសព្វ ភ្លឺប្រាល ឡៃទាល សន្ធោសន្ធៅ តាំងនៅបន្ទាប់គ្នានឹងកុក្កុលនរកនោះឯង ។ ពួកនិរយបាល ក៏ប្រើបុរសនោះឲ្យឡើងឲ្យចុះអំពីព្រៃរកានោះ ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាលើដើមរកានោះ បើបាបកម្ម មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ មានព្រៃស្លោសសិតធំ តាំងនៅបន្ទាប់គ្នានឹងព្រៃរកានោះឯង ។ បុរសនោះ ចូលទៅក្នុងព្រៃស្លោសសិតនោះ ។ ខ្យល់បក់ស្លឹកសសិតនោះ មកកាត់ដៃ កាត់ជើង កាត់ទាំងដៃទាំងជើង កាត់ស្លឹកត្រចៀក កាត់ច្រមុះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះ (របស់បុរសនោះ) ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងព្រៃសសិតនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ មានស្ទឹងទឹកផ្សាដ៏ធំ តាំងនៅបន្ទាប់គ្នានឹងព្រៃសសិតនោះឯង ។ បុរសនោះ ក៏ធ្លាក់ទៅក្នុងស្ទឹងនោះ ។ បុរសនោះ ជួនកាលអណ្តែតបណ្តោយខ្សែទឹក ជួនកាលអណ្តែតច្រាសខ្សែទឹក ជួនកាលអណ្តែតទាំងបណ្តោយទាំងច្រាសខ្សែទឹក

ក្នុងស្ទឹងនោះ ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងស្ទឹងនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកសន្ទូច ស្ទូចបុរសនោះវាត់ឡើង ដាក់មកលើគោក ហើយសួរយ៉ាងនេះថា នែបុរស អ្នកឯងប្រាថ្នាអ្វី ។ បុរសនោះ ឆ្លើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំឃ្លានបាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏យកកន្ទ្រៃដែកដ៏ក្ដៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយញាត់នូវដុំទង់ដែងដ៏ក្ដៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ។ ដុំទង់ដែងនោះ ក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំ ទាំងពោះវៀនតូច របស់បុរសនោះ ចេញមកក្រោម ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងនរកនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល សួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស អ្នកឯងប្រាថ្នាអ្វី ? បុរសនោះ ឆ្លើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំស្រេកទឹក ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកកន្ធ្វេរដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយបន្តក់ទឹកទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ។ ទឹកទង់ដែងនោះ ក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំទាំងពោះវៀនតូច របស់បុរសនោះចេញមកខាងក្រោម ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងនរកនោះ បើបាបកម្មនោះមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល បោះទំលាក់បុរសនោះ ទៅក្នុងមហានរកវិញ ។

ម្នាលភិក្ខុទាំងឡាយ រឿងរ៉ាវ ធ្លាប់មានមកហើយថា ព្រះយមរាជ មានសេចក្តីត្រិះរិះដូច្នេះថា បានឮថា សត្វទាំងឡាយ

ណា ធ្វើបាបកម្មក្នុងលោក សត្វទាំងនោះឯង រមែងត្រូវគេធ្វើកម្មករណ៍ផ្សេងៗ មានសភាពយ៉ាងនេះ ឱហ្ន៎ អាត្មាអញ សូមឲ្យបានអត្តភាពជាមនុស្ស ឲ្យទាន់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធត្រាស់ឡើងក្នុងលោក សូមឲ្យអាត្មាអញ ចូលទៅអង្គុយជិតព្រះមានព្រះភាគអង្គនោះ បើព្រះមានព្រះភាគអង្គនោះ ទ្រង់សម្តែងធម៌ប្រោសអាត្មាអញ សូមឲ្យអាត្មាអញយល់ច្បាស់នូវធម៌របស់ព្រះមានព្រះភាគអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ឯតថាគតមិនមែនបានស្តាប់រឿងនោះឯង អំពីសមណៈ ឬព្រាហ្មណ៍ដទៃណាមួយ ហើយ (នាំមក) សម្តែងទេ តាមដែលពិតនោះតថាគតសម្តែងរឿងដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង យល់ខ្លួនឯង តែមួយយ៉ាង ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ លុះព្រះសុគត ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ទើបព្រះ-សាស្តា ទ្រង់ត្រាស់និពន្ធគាថានេះតទៅថា ៖

មាណពទាំងឡាយណា ដែលយមរាជ ដាស់តឿនដោយ
ទេវទូតទាំងឡាយហើយ ក៏នៅតែប្រមាទ មាណពទាំងនោះ

ឯង ជាអ្នកបាននូវកាយដ៏ថោកទាប រមែងសោកសៅ អស់កាលយូរអង្វែង ចំណែកមាណពណា ក្នុងលោកនេះ ជាសប្បុរស មានសន្តានស្ងប់រម្ងាប់ ដែលយមរាជ ដាស់តឿនដោយទេវទូតទាំងឡាយហើយ តែងមិនប្រមាទ ក្នុងអរិយធម៌ ក្នុងកាលណាឡើយ រមែងឃើញនូវភ័យ ក្នុងឧបាទាន ជាហេតុកើតឡើងនៃជាតិនិងមរណៈ តែងចុះ ចិត្តស៊ប់ក្នុងព្រះនិព្វាន ជាធម្មជាតអស់ទៅនៃជាតិ និង មរណៈ ព្រោះមិនប្រកាន់មាំ មាណពនោះឯង ជាអ្នកដល់ នូវទីដ៏ក្សេម មានសេចក្តីសុខ រលត់កិលេស ក្នុងបច្ចុប្បន្ន ជាអ្នកកន្លងផុតនូវពៀរ និងភ័យទាំងពួង បានឆ្លងផុតនូវទុក្ខ ទាំងពួង ។

ចប់ ទេវទូតសូត្រ ទី១០ ។

(បាក សុត្តន្តបិដក លេខ ២៧)

# អដ្ឋកថាទេវទូតសូត្រ

ក្នុងអដ្ឋកថា មនោរថបូរណី លោកពន្យល់ទុកថា ៖

បទថា ទេវទូតានិ បានដល់ ទេវទូតទាំងឡាយៗ ក៏ក្នុងបទថា ទេវទូតានិ នេះ មានអត្ថន័យរបស់ពាក្យដូចតទៅនេះ ៖

មច្ចុឈ្មោះថា **ទេវៈ**, ទូតរបស់ទេវៈនោះ ឈ្មោះថា ទេវទូត អធិប្បាយថា អ្នកចាស់ អ្នកឈឺ និងអ្នកស្លាប់ ហៅថា **ទេវទូត** ព្រោះដូចជាដាស់តឿនថា "ឥទានិ តេ មច្ចុសមីបំ គន្តព្វំ : ឥឡូវនេះ លោកកំពុងចូលទៅជិតសេចក្ដីស្លាប់" ដោយសំដៅយកនឹងឲ្យកើតសេចក្ដីសង្វេគ ។

មួយទៀត ឈ្មោះថា **ទេវទូត** ព្រោះសំដៅសេចក្ដីថា ជាទូតដូចជាទេវតាខ្លះ ។ អធិប្បាយថា កាលទេវតាប្រដាប់តាក់តែងហើយ ឈរនិយាយនៅក្នុងអាកាសថា "ត្វំ អសុកទិវសេ មរិស្សសិ : លោកនឹងស្លាប់ក្នុងថ្ងៃឯណោះ" ពាក្យនិយាយរបស់ទេវតានោះអ្នកត្រូវជឿយ៉ាងណា សូម្បីអ្នកចាស់ អ្នកឈឺ និងអ្នកស្លាប់ ក៏ដូច្នោះដែរ កាលប្រាកដក៏ដូចជាដាស់តឿនថា សូម្បីលោកក៏មានយ៉ាងនេះជាធម្មតា ក៏ពាក្យនិយាយនោះ របស់អ្នកចាស់ អ្នកឈឺ និងអ្នកស្លាប់ទាំងនោះ ក៏ដូចជា

ពាក្យព្យាករណ៍របស់ទេវតា ព្រោះមិនផ្លាស់ប្តូរទៅជាយ៉ាងដទៃឡើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ទេវទូត** ព្រោះជាទូតដូចជាទេវតា ។

ម្យ៉ាងទៀត ឈ្មោះថា **ជាទេវទូត** ព្រោះជាទូតរបស់វិសុទ្ធិទេវៈ ក៏បាន, អធិប្បាយថា ព្រះពោធិសត្វគ្រប់អង្គឃើញអ្នកចាស់ អ្នកឈឺ អ្នកស្លាប់ និងអ្នកបួសប៉ុណ្ណោះ ក៏ដល់សេចក្តីសង្វេគ ហើយចេញបួស ។ អ្នកចាស់ អ្នកឈឺ អ្នក-ស្លាប់ និងអ្នកបួស ឈ្មោះថា **ទេវទូត** ព្រោះជាទូតរបស់វិសុទ្ធិទេវៈទាំងឡាយខ្វះ ដូចពណ៌នាមកនេះ ។ តែក្នុងសូត្រនេះលោកពោលថា ទេវទូតានិ ព្រោះលិង្គវិបល្លាស ។

សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ផ្តើមពាក្យថា កាយេន ទុច្ចរិតំ (ទុច្ចរិតដោយកាយ) ជាដើមទុក ?

ឆ្លើយថា ដើម្បីទ្រង់សម្តែងដល់កម្មរបស់អ្នកចូលដល់ឋានៈ ដែលជាហេតុ (ឲ្យយមរាជ) នាំសួរដល់ឋានៈរបស់ទេវទូតទាំងឡាយ ។ ពិតមែន សត្វនេះ រមែងកើតក្នុងនរកដោយកម្មនេះ ។ យមរាជ រមែងសាកសួរទេវទូតទាំងឡាយ ។ បណ្តាបទទាំងនោះ បទថា កាយេន ទុច្ចរិតំ ចរតិ សេចក្តី

ថា ប្រព្រឹត្តទុច្ចរិត ៣ យ៉ាង តាមកាយទ្វារ ។ បទថា វាចាយ សេចក្តីថា ប្រព្រឹត្តទុច្ចរិត ៤ យ៉ាង តាមវចីទ្វារ ។ បទថា មនសា សេចក្តីថា ប្រព្រឹត្តទុច្ចរិត ៣ យ៉ាង តាមមនោទ្វារ ។

ក្នុងអដ្ឋកថា បបញ្ចសូទនី ពន្យល់ថា ៖

បទថា និរយំ ឧបបន្នា (កើតក្នុងកំណើតនរក) សេចក្តីថា ក្នុងគ្រាខ្លះព្រះមានព្រះភាគ ទ្រង់ញ៉ាំងទេសនាតាំងពីនរក ឲ្យចប់ស្រេចដោយទេវលោក ។ គ្រាខ្លះតាំងពីទេវលោក ទ្រង់ឲ្យចប់ស្រេចដោយនរក ។ បើព្រះអង្គប្រាថ្នានឹងត្រាស់សួគ៌សម្បត្តិឲ្យពិស្តារ ព្រះអង្គត្រាស់ដល់សេចក្តីទុក្ខក្នុងនរក ដោយឯកទេស (គឺតិចតួច) ទុក្ខក្នុងកំណើតសត្វតិរច្ឆាន ទុក្ខក្នុងបិត្តិវិស័យ ត្រាស់ដល់សម្បត្តិក្នុងមនុស្សលោក ដោយឯកទេស ។ បើថា ប្រាថ្នានឹងត្រាស់ទុក្ខក្នុងនរកឲ្យពិស្តារ រមែងត្រាស់ដល់សម្បត្តិក្នុងទេវលោក មនុស្សលោក និងទុក្ខក្នុងកំណើតសត្វតិរច្ឆាន និងបិត្តិវិស័យ ដោយឯកទេស, ព្រះអង្គញ៉ាំងទុក្ខក្នុងនរកឲ្យពិស្តារ, ក្នុងព្រះសូត្រនេះ ព្រះអង្គប្រាថ្នានឹងទ្រង់ញ៉ាំងទុក្ខក្នុងនរកឲ្យពិស្តារ ព្រោះដូច្នោះ ទ្រង់ទេសនាតាំងពីទេវលោក ឲ្យចប់ស្រេច

ដោយនរក ដើម្បីនឹងត្រាស់ដល់សម្បត្តិក្នុងទេវលោក មនុស្ស-លោក និងទុក្ខក្នុងកំណើតសត្វតិរច្ឆាន និងក្នុងបិត្តិវិស័យ ដោយឯកទេស ហើយត្រាស់ដល់ទុក្ខក្នុងនរក ដោយពិស្តារ, ទើបត្រាស់ពាក្យជាដើមថា តមេនំ ភិក្ខវេ និរយបាលា (ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល) ។

ក្នុងបទនោះ ព្រះថេរៈពួកខ្លះពោលថា ឈ្មោះថា នាយនិរយបាល មិនមានទេ កម្មប៉ុណ្ណោះ រមែងបង្កើតហេតុ ដូចរូបយន្ត ។ កម្មនោះ ត្រូវបដិសេធទុកក្នុងអភិធម្ម ដោយន័យជាដើមថា “អើ និរយបាលក្នុងនរកមាន និងហេតុនៃកម្មក៏មាន” ។ ឧបមាថា ក្នុងមនុស្សលោក មានអ្នកដាក់ទោសដោយកម្មករណ៍ យ៉ាងណា នាយនិរយបាលក៏មាននៅក្នុងនរកដូច្នោះ ។

បទថា **យមស្ស រញ្ញោ** (ព្រះយមរាជ) បានដល់ ព្រះ-រាជាវេមានិកប្រេត ឈ្មោះថា **យមរាជ**, ក្នុងវេលាខ្លះ សោយសម្បត្តិ គឺមានដើមកប្បព្រឹក្សជាទិព្វ ឧទ្យានជាទិព្វ អ្នករបាំជាទិព្វ សម្បត្តិទិព្វ ក្នុងវិមានទិព្វ, ក្នុងវេលាខ្លះ ជាព្រះរាជាអ្នកទ្រង់ធម៌ សោយផលកម្ម ។ ស្តេចយមរាជមិនមែនមានតែ ១

អង្គទេ, តែមាន ៤ អង្គ ក្នុងទ្វារទាំង ៤ ។ បទថា ឆាទ្ទសំ (មិនបានឃើញទេ) សេចក្តីថា លោកសំដៅយកនូវភាពមិនមាននៃទេវទូត ដែលអ្នកណាមួយ ត្រូវគេបញ្ជូនទៅក្នុងសំណាក់របស់ខ្លួន ទើបពោលយ៉ាងនេះ ។ គ្រានោះយមរាជ ដឹងថា អ្នកនេះមិនអាចកំណត់សេចក្តីនៃភាសិត ប្រាថ្នានឹងឲ្យគេកំណត់ ទើបពោលពាក្យថា **អម្ភោ** ។

បទថា ជាតិធម្មោ (មានជាតិជាធម្មតា) គឺមានការកើតជាសភាព មិនផុតពីការកើតទៅបាន ឈ្មោះថា **ជាតិ** រមែងប្រព្រឹត្តទៅក្នុងខាងក្នុងរបស់យើង ។ សូម្បីក្នុងបទជាដើមថា បរតោ ជរាធម្មោ ក៏មានន័យនេះដូចគ្នា ។

## ទេវទូត ទី១

ក្នុងបទថា បឋមំ ទេវទូតំ សមនុយុញ្ជិត្វា (សាកសួរដេញដោលនូវទេវទូតទី១) សេចក្តីថា **ក្មេងខ្ចី** រមែងពោលយ៉ាងនេះ ដោយសេចក្តីថា អ្នកដ៏ចម្រើន ចូរមើលយើង សូម្បីយើងក៏មានដៃនិងជើង ដូចជាពួកលោក តែយើងដេកនៅក្នុងមូត្រនិងលាមករបស់ខ្លួន មិនអាចដើម្បីនឹងក្រោកឡើងងូតទឹកតាម

ធម្មតារបស់ខ្លួនបាន យើងជាអ្នកមានកាយស្មោកគ្រោកហើយ មិនអាចដើម្បីនឹងប្រាប់ថា អ្នកទាំងឡាយចូរផ្លូតទឹកឲ្យយើង, យើងប្រាកដដូច្នេះ ព្រោះមិនផុតពីការកើត ។ តាមពិតទៅ មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីលោកទាំងឡាយក៏មិនផុតពីការកើត ។ ការកើតនឹងមកដល់សូម្បីដល់លោកទាំងឡាយ ដូចយើង លោកចូរធ្វើសេចក្តីល្អទុកតាំងពីមុនកើតនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង ក្មេងខ្ចីនោះ ឈ្មោះថា ទេវទូត ។ តែសេចក្តីនៃពាក្យ គឺលោកពោលទុកហើយក្នុងមយទេវសូត្រ។

## ទេវទូត ទី២

សូម្បីក្នុងបទថា ទុតិយំ ទេវទូតំ (ទេវទូតទី២) នេះសេចក្តីថា **សត្វចាស់ជរា** ឈ្មោះថា រមែងពោលយ៉ាងនេះ ដោយសេចក្តីថា អ្នកដ៏ចម្រើន ពួកលោកចូរមើល សូម្បីយើងក៏ធ្លាប់ជាកំលោះ បរិបូរណ៍ដោយកម្លាំងជើង កម្លាំងដៃ និងរហ័សរហួន ដូចលោក ការដល់ព្រមដោយកម្លាំង និងសេចក្តីរហ័សរហួនទាំងនោះ របស់យើងនោះ សូន្យអស់ទៅហើយ សូម្បីដៃនិងជើងរបស់យើងមាន ក៏ធ្វើកិច្ចដោយដៃនិងជើង មិន

បាន, យើងប្រាកដដូចនេះ ព្រោះមិនផុតពីជរា ។ តាមពិតទៅ មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីលោកទាំងឡាយ ក៏មិនរួចផុតទៅពីជរាដែរ ភាពជរានឹងមកដល់លោកទាំងឡាយដូចយើងដែរ លោកទាំងឡាយ ចូរធ្វើសេចក្ដីល្អទុកមុនអំពីការជរានោះនឹងមកដល់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង សត្វចាស់ជរានោះ ឈ្មោះថា **ទេវទូត** ។

## ទេវទូត ទី៣

សូម្បីក្នុងបទថា តតិយំ ទេវទូតំ (ទេវទូតទី៣) នេះ សេចក្ដីថា **សត្វអ្នកឈឺ** ឈ្មោះថា រមែងពោលយ៉ាងនេះ ដោយសេចក្ដីថា អ្នកដ៏ចម្រើនពួកលោកចូរមើល សូម្បីយើងក៏ជាអ្នកមិនមានរោគដូចលោក យើងនោះឥឡូវនេះ ត្រូវព្យាធិគ្របសង្កត់ ដេកត្រាំនៅក្នុងទឹកមូត្រ និងលាមករបស់ខ្លួន មិនអាចដើម្បីនឹងក្រោកឡើងបាន សូម្បីដៃនិងជើងរបស់យើងមាន ធ្វើកិច្ចដោយដៃនិងជើងមិនបានឡើយ យើងប្រាកដដូចនោះ ព្រោះមិនផុតពីព្យាធិ ។ តាមពិតទៅ មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីលោកទាំងឡាយក៏មិនរួចផុតពីព្យាធិ ។ ព្យាធិនឹងមកដល់យើងយ៉ាងណា ព្យាធិនឹងមកដល់លោកទាំងឡាយយ៉ាងនោះ, លោកចូរធ្វើ

សេចក្ដីល្អទុកមុនអំពីព្យាធិនឹងមកដល់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ សត្វអ្នកឈឺនោះ ឈ្មោះថា **ទេវទូត** ។

## ទេវទូត ទី៤

ក៏ក្នុងបទថា ចតុត្ថំ ទេវទូតំ (ទេវទូតទី៤) នេះ កម្មករណ៍ ឬអ្នកដាក់ទោស ឈ្មោះថា **ទេវទូត** ។ ក្នុងពីរបទនោះ ក្នុងចំណែកកម្មករណ៍ កម្មករណ៍ ៣២ មុន រមែងពោលយ៉ាងនេះ ដោយអត្ថថា ពួកយើងកាលកើត រមែងមិនកើតក្នុងដើមឈើ ឬក្នុងថ្មទេ គឺរមែងកើតក្នុងសរីរៈរបស់បុគ្គលដូចជាលោក ដោយប្រការដូច្នេះ លោកចូរធ្វើសេចក្ដីល្អទុកមុនយើងកើត ព្រោះហេតុនោះ កម្មករណ៍ទាំងនោះ ទើបឈ្មោះថា **ទេវទូត** ។

សូម្បីអ្នកដាក់ទោស រមែងពោលយ៉ាងនេះ ដោយអត្ថថា ពួកយើងកាលនឹងដាក់កម្មករណ៍ ៣២ យ៉ាង មិនបានដាក់ក្នុងដើមឈើជាដើមទេ រមែងដាក់ក្នុងសត្វដូចពួកលោកទុំះឯង ។ ដោយប្រការដូច្នេះ ពួកលោកចូរធ្វើសេចក្ដីល្អមុនដែលយើងនឹងដាក់ទោស ។ ព្រោះហេតុនោះ សូម្បីអ្នកដាក់ទោសទាំងនោះ ឈ្មោះថា **ទេវទូត** ។

# ទេវទូត ទី៥

ក្នុងបទថា បញ្ចមំ ទេវទូតំ (ទេវទូតទី៥) នេះ សេចក្ដីថា សត្វអ្នកស្លាប់ហើយ រមែងពោលយ៉ាងនេះ ដោយអត្ថថា អ្នកដ៏ចម្រើន ពួកលោកចូរមើលយើងដែលគេទុកចោលក្នុងព្រៃជាទីចោលសាកសព ដល់នូវភាពកំពុងហើមប៉ោងជាដើម យើងប្រាកដដូច្នេះ ព្រោះមិនផុតពីសេចក្ដីស្លាប់ ។ តាមពិតទៅ មិនមែនតែយើងប៉ុណ្ណោះទេ សូម្បីពួកលោកក៏មិនផុតពីសេចក្ដីស្លាប់ដូចគ្នាដែរ សេចក្ដីស្លាប់នឹងមកដល់លោកទាំងឡាយដូចយើងដែរ ព្រោះហេតុនោះ ពួកលោកចូរធ្វើសេចក្ដីល្អទុកមុនសេចក្ដីស្លាប់នោះនឹងមកដល់ ។ ព្រោះដូច្នោះ សត្វអ្នកស្លាប់នោះ ឈ្មោះថា ទេវទូត ។

## អ្នកត្រូវសាកសួរទេវទូត

សួរថា សត្វណាដែលគួរបានសួរដេញដោលអំពីទេវទូតនេះ សត្វណាដែលមិនគួរបានសួរដេញដោល ។ ឆ្លើយថា សត្វណាធ្វើបាបកម្មច្រើន សត្វនោះ ទៅកើតក្នុងនរកតែម្ដង ។ សត្វណាធ្វើបាបកម្មតិចតួច សត្វនោះ រមែងបាន (ការសាកសួរដេញដោលទេវទូត) ។ រឿងនេះ ដូចគ្នានឹងរាជបុរសដែលចាប់

ចោរបាន ព្រមទាំងទ្រព្យជាព័ស្តុតាង ហើយយកមកដាក់ទោស តែម្តង មិនបាច់វិនិច្ឆ័យ (ជំនុំជំរះ) ។ ចំណែកចោរណា ដែល ចាប់បានល្មមនឹងដេញដោលសាកសួរ ក៏យកទៅកាន់សាលា វិនិច្ឆ័យ ឲ្យសាកសួរមើលសិន ក៏ដូច្នោះ ។ ពិតមែន អ្នកមាន បាបកម្មតិចតួច ចួនកាលរលឹកបានតាមធម្មតារបស់ខ្លួនឯង ចួនកាលទាល់តែគេរំលឹក ក៏រលឹកបាន ។ ក្នុងសេចក្តីនោះ មាន ទមិឡ្ស ឈ្មោះទីឃជយន្ត រលឹកបានតាមធម្មតារបស់ខ្លួន ។

បានឮថា ទមិឡ្សនោះ យកសំពត់ពណ៌ក្រហម បូជា អាកាសចេតិយ ក្នុងសុមនគិរីវិហារ ។ គ្រានោះ គេកើតជិត ឧស្សទនរក បានឮសំឡេងអណ្តាតភ្លើង រលឹកដល់សំពត់ដែល ខ្លួនបូជាទុក ។ គេទើបទៅកើតក្នុងសួគ៌ ។

ម្នាក់ទៀត ថ្វាយសំពត់សាដកសាច់រលោង (**ខលិសា-ជកំ**) ដល់ភិក្ខុកំលោះដែលជាបុត្រ ដាក់ទៀបជើង ។ ក្នុងវេលា ជិតស្លាប់ គេកាន់យកនិមិត្តក្នុងសំឡេងថា **បដ: បដ:** សូម្បី គេកើតជិតឧស្សទនរក ក៏រលឹកដល់សំពត់នោះ ព្រោះសំឡេង អណ្តាតភ្លើង ទើបទៅកើតក្នុងសួគ៌ ។ គេរលឹកដល់កុសល-កម្មតាមធម្មតារបស់ខ្លួនមុនយ៉ាងនេះ ទើបកើតក្នុងសួគ៌ ។

តែកាលរលឹកតាមធម្មតារបស់ខ្លួនឯងមិនបាន ទើបសួរទេវទូតទាំង ៥ ។ ក្នុងទេវទូតទាំង ៥ នោះ អ្នកខ្លះរលឹកបានដោយទេវទូតទីមួយ ។ អ្នកខ្លះរលឹកបានដោយទេវទូតទីពីរជាដើម ។ ចំណែកអ្នកណា រមែងរលឹកមិនបានដោយទេវទូតទាំង ៥ ស្តេចយមរាជ ឲ្យអ្នកនោះរលឹកបានឯង ។ បានឮថាអាមាត្យម្នាក់ បូជាមហាចេតិយដោយក្រុមផ្កាម្ទេះ បានឲ្យចំណែកបុណ្យដល់ស្តេចយមរាជ ។ នាយនិរយបាល នាំអាមាត្យនោះអ្នកកើតក្នុងនរក ព្រោះអកុសលកម្ម ទៅរកស្តេចយមរាជ ។ កាល អាមាត្យនោះ រលឹកមិនបានដោយទេវទូតទាំង ៥ ស្តេចយមរាជ ត្រួតមើលឃើញហើយឲ្យរលឹកថា លោកបូជាមហាចេតិយ ដោយក្រុមផ្កាម្ទេះហើយផ្សាយចំណែកបុណ្យឲ្យយើង មិនមែនឬ, គេរលឹកបានក្នុងវេលានោះហើយ ទៅកាន់ទេវលោក ។ ក៏ប៉ុន្តែថា ស្តេចយមរាជ សូម្បីត្រួតមើលក៏មិនឃើញ ត្រិះរិះថា សត្វនេះនឹងសោយទុក្ខធំ ទើបទ្រង់នៅស្ងៀម ។

បទថា **មហានិរយេ** (ក្នុងមហានរក) បានដល់ អវីចិមហានរក ។ សួរថា អវីចិមហានរកនោះ ប្រមាណប៉ុនណា ។ ឆ្លើយថា ខាងក្នុងមានបណ្តោយ និងដោយទទឹង ប្រមាណ

១០០ យោជន៍ដូចគ្នា ។ ផែនដីលោហៈ ដំបូលលោហៈ និង កម្ពស់ជញ្ជាំងម្ខាងៗ ប្រមាណ ៨១ យោជន៍[១] ។ អណ្ដាត-ភ្លើងនោះ តាំងឡើងក្នុងទិសបូព៌ាទល់ជញ្ជាំងទិសបច្ចិម បាក់ធ្លុះជញ្ជាំងនោះ ទៅខាងមុខ ១០០ យោជន៍ ។ សូម្បីក្នុងទិសដ៏សេស ក៏មានន័យនេះឯង ។ ដោយប្រការដូច្នេះ ដោយផ្នែកបណ្ដោយ និងផ្នែកទទឹង ដោយទីបំផុតរបស់អណ្ដាតភ្លើង មានប្រមាណ ៣១៨ យោជន៍ ។ តែដោយជុំវិញ មានប្រមាណ ៩៥៤ យោជន៍ ។ ចំណែកដោយជុំវិញ ប្រមាណមួយម៉ឺន-យោជន៍ មួយអន្លើដោយឧស្សទនរក ។

ក្នុងបទថា ឩត្ថតំ តាធិសមេវ ហោតិ (ភ្លើងក៏នៅតែឆេះដូច្នោះឯង) នេះ សេចក្ដីថា មិនអាចនឹងលើកជើងដែលជាន់ជរាបដល់ឆ្អឹង ឲ្យរឹងមាំបាន ។ ក៏ក្នុងបទនេះ មានអធិប្បាយដូច្នេះ ត្រូវដុតឆេះទាំងខាងក្រោម ខាងលើ ។ ដោយប្រការដូច្នេះ ក្នុងវេលាជាន់ប្រាកដ ត្រូវអណ្ដាតភ្លើងដុតឆេះ ក្នុងវេលាលើកឡើង ក៏ជាដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោល

---

១ ក្នុងបិដក ខ្មែរ ថា ខាងបណ្ដោយនិងទទឹង ៩០០ យោជន៍ដូចគ្នា ។ កម្ពស់ជញ្ជាំងមួយៗ ៩ យោជន៍ ។ សេចក្ដីនេះ មិនត្រូវជាមួយនឹងច្បាប់ឆដ្ឋ. និងច្បាប់ដទៃខ្លះ។

យ៉ាងនេះ ។ បទថា ពហុសម្បត្តោ (ជាច្រើនឆ្នាំ) គឺ ដល់ច្រើនសែនឆ្នាំ ។

សួរថា ព្រោះហេតុអ្វី នរកនេះទើបឈ្មោះថា **អវីចិ** ។ ឆ្លើយថា លោកហៅ ចន្លោះ ថា **វីចិ** ។ ក្នុងនរកនោះ មិនមានចន្លោះអណ្តាតភ្លើង មិនមានចន្លោះសត្វ ឬមិនមានចន្លោះសេចក្តីទុក្ខ ព្រោះដូច្នោះ នរកនោះ ទើបឈ្មោះថា **អវីចិ** ។ អណ្តាតភ្លើងតាំងឡើងពីជញ្ជាំងផ្នែកខាងទិសបូព៌ា របស់នរកនោះ សាយជះទៅ ១០០ យោជន៍ ចាក់ធ្លុះជញ្ជាំងទៅខាងមុខ ១០០ យោជន៍ ។ សូម្បីក្នុងទិសដ៏សេស ក៏មានន័យនេះឯង ។

ទេវទត្ត កើតក្នុងកណ្តាលនៃអណ្តាតភ្លើងទាំង ៦ នេះ ។ ទេវទត្តមានអត្តភាពប្រមាណ ១០០ យោជន៍ ជើងទាំងពីរចូលទៅកាន់ផែនដីលោហៈដល់កជើង ដៃទាំងពីរចូលទៅកាន់ជញ្ជាំងលោហៈដល់កដៃ ។ សីសៈចូលទៅដំបូលលោហៈ ដល់ឆ្អឹងចិញ្ចើម ។ លំពែងលោហៈមួយចូលទៅដោយចំណែកក្រោមធ្លុះកាយទៅទល់ដំបូល ។ លំពែងចេញពីជញ្ជាំងផ្នែកខាងទិសបូព៌ា ចាក់ធ្លុះបេះដូងចូលទៅជញ្ជាំងផ្នែកខាងទិសបច្ចិម លំពែងចេញចាកជញ្ជាំងផ្នែកខាងទិសឧត្តរ ចាក់ធ្លុះឆ្អឹងជំនីរ ទៅទល់ជញ្ជាំង

ផ្នែកខាងទិសទក្សិណ ។ ទេវទត្តប្រាកដដូច្នេះ ព្រោះផលកម្ម ដែលថា ទេវទត្តកប់នេះ ព្រោះខុសក្នុងព្រះតថាគត ទ្រង់មិន-ញាប់ញ័រ ។ ដោយប្រការដូច្នេះ នរកឈ្មោះថា **អវីចិ** ព្រោះអណ្តាតភ្លើងមិនមានចន្លោះ ។

ក្នុងខាងក្នុងនរកនោះ ក្នុងទីប្រមាណ ១០០ យោជន៍ សត្វមិនមានចន្លោះ (ចង្អៀតគ្នា) ដូចម្សៅដែលគេញាត់ដាក់ទុកក្នុងនាឡិ មិនគួរពោលថា ក្នុងទីនេះមានសត្វ ក្នុងទីនេះមិនមាន ។ សត្វដើរ ឈរ អង្គុយ និងដេកមិនមានទីបំផុត ។ សត្វទាំងឡាយកាលដើរ ឈរ អង្គុយ ឬដេក រមែងមិនបៀតបៀននូវគ្នានឹងគ្នា ។ ឈ្មោះថា **អវីចិ** ព្រោះសត្វទាំងឡាយ មិនមានចន្លោះយ៉ាងនេះ ។

ចំណែកក្នុងកាយទ្វារ ចិត្តសហគតដោយឧបេក្ខា ៦ ដួង រមែងកើតឡើងមួយដួងសហគតដោយទុក្ខ ។ សូម្បីកាលជាយ៉ាងនេះ កាលបុគ្គលដាក់តំណក់ទឹកឃ្មុំ ៦ តំណក់ ទុកត្រង់ចុងអណ្តាត តំណក់មួយដាក់ត្រង់តម្លលោហ: ព្រោះត្រូវដុតបំផ្លាញ កម្លាំងតំណក់ទឹកនោះ រមែងប្រាកដ, ក្រៅនេះជាអព្វោហារិក, យ៉ាងណា ទុក្ខក្នុងនរកនេះ មិនមានចន្លោះ ព្រោះ

មានការដុតឆេះជាកម្លាំង ទុក្ខក្រៅនេះជាអញ្ចោហារិក ដូច្នោះ ។ ឈ្មោះថា អវីចិ ព្រោះមិនមានចន្លោះដោយទុក្ខយ៉ាងនេះឯង ។

បទថា មហាន្តោ (ដ៏ធំ) គឺប្រមាណ ១០០ យោជន៍ ។ បទថា សោ តត្ថ បតតិ (បុរសនោះធ្លាក់ទៅក្នុងគូថនរកនោះ) សេចក្តីថា ដើងម្ខាងនៅក្នុងមហានរក ។ ម្ខាងធ្លាក់ទៅក្នុងគូថ-នរក ។ បទថា សូចិមុខា (មាត់ស្រួចដូចម្ជុល) គឺមានមាត់ដូចជាម្ជុល ។ សត្វទាំងនោះមានកប៉ុនដំរី និងប៉ុនទូកទោណិកមួយ ។

បទថា កុក្កុលនិរយោ (កុក្កុលនរក) សេចក្តីថា នរកផេះរងើកក្តៅ ពេញទៅដោយផេះប្រាសចាកភ្លើង ខាងក្នុងផុះកំពូលប្រមាណ ១០០ យោជន៍ ។ សត្វដែលធ្លាក់ទៅក្នុងនរកដល់ផែនដីក្រោម ដូចគ្រាប់ស្ពៃ ក្នុងគំនរស្ពៃដែលគេគ្រវែងទៅក្នុងរណ្តៅរងើកភ្លើង ។

បទថា អាកោដេន្តិ (ប្រើឲ្យឡើង) សេចក្តីថា យកដំបងដែកវាយឲ្យឡើង ។ ក្នុងវេលាលើកដំបងដែកទាំងនោះឡើង បន្ទាដែកនៅខាងក្រោម វេលាដាក់ចុះបន្ទាដែកនៅខាង-លើ ។ បទថា វាតេរិតានិ (ខ្យល់បក់) បានដល់ បក់កម្រើក

ទៅដោយកម្ម ។ បទថា ហត្ថម្បិ ឆិន្ទន្តិ (កាត់ដៃ) សេចក្តីថា បានដល់ កាត់ជំរៀកដូចរៀកសាច់លើជ្រុញ ។ បើក្រោកឡើងរត់ទៅបាន កំពែងដែកផុសឡើង មកលោមព័ទ្ធទុកមុខនៃកាំបិតកោ ក៏តាំងឡើងខាងក្រោម ។

បទថា ខារោទកា នទី (ស្ទឹងទឹកផ្សា) បានដល់ ស្ទឹងទឹកទន់ដែង (តម្ពលោហនទី) ឈ្មោះថា **វេតរណី**។ ក្នុងបទនោះ ខ្សាច់គ្រោតគ្រាត សម្រេចដោយដែក ស្ទឹកឈូកខាងក្រោម មានមុខនៃកាំបិតកោ ត្រង់ច្រាំងពីរមានវល្លិផ្តៅនិងស្បូវ ។ បទថា សោ តត្ថ ទុក្ខា តិព្វា ១រា (បុរសនោះ រងទុក្ខក្លាខ្លាំង ខ្លោចផ្សាក្នុងស្ទឹងនោះ) សេចក្តីថា សត្វនរកនោះ អណ្តែតឡើងខាងលើ និងចុះទៅខាងក្រោម ក្នុងនរកជាប់ក្នុងស្ទឹកឈូក ។ ត្រូវបន្ទាខ្សាច់គ្រោតគ្រាត មានសណ្ឋានជា **សិង្ឃាដក** ត្រូវពុះដោយមុខកាំបិតកោ រមែងកូតដោយស្បូវត្រង់ច្រាំងទាំងពីរខាង ។ ទាញមកដោយវល្លិផ្តៅ ។ ត្រូវពុះដោយសស្រ្តាដែលមុត ។

បទថា តត្តេន អយោសង្កុនា (យកកង្វេរដែកដ៏ក្តៅនោះ) សេចក្តីថា កាលសត្វនរក ពោលថា ខ្ញុំឃ្លាន នាយ-

និរយបាលទាំងនោះ យកដុំលោហៈបំពេញកញ្ជ្រែងលោហៈធំ យកចូលទៅឲ្យគេ ។ គេដឹងថា ជាដុំលោហៈប៉ះត្រង់ធ្មេញគ្រានោះ នាយនិរយបាល យកកន្ត្រៃដែកដ៏ក្តៅមកបើកមាត់របស់គេ ។ យកទឹកទង់ដែងដ៏ក្តៅ ដាក់ចូលទៅក្នុងផើងលោហៈធំ ហើយធ្វើយ៉ាងនោះឯង ។ បទថា បុន មហានិរយេ (ក្នុងមហានរកទៀត) សេចក្តីថា នាយនិរយបាលឲ្យដាក់ទោស តាំងពីបញ្ចពិធព័ន្ធន៍ (ចំណងប្រាំប្រការ) រហូតដល់ផឹកទឹកទង់ដែងយ៉ាងនេះ តាំងពីផឹកទឹកទង់ដែងឲ្យដាក់ចុះរហូតដល់បញ្ចពិធ-ព័ន្ធន៍ជាដើមទៀត បោះចុះទៅក្នុងមហានរក ។ ក្នុងមហានរកនោះ ខ្លះរួចផុតចំណង ៥ ប្រការ, ខ្លះរួចផុតគ្រាទីពីរ, ខ្លះរួចផុតគ្រាទីបី, ខ្លះរួចផុតដោយការផឹកទឹកទង់ដែង ។ ក៏កាលមិនទាន់អស់កម្ម នាយនិរយបាលក៏បោះចុះទៅក្នុងមហានរកទៀត ។

ក៏ភិក្ខុកំលោះមួយរូប កាលរៀនព្រះសូត្រនេះ ពោលថា លោកម្ចាស់ដ៏ចម្រើន កាលសត្វនរកសោយទុក្ខប៉ុណ្ណេះហើយ នាយនិរយបាលនៅបោះគេទៅក្នុងមហានរកទៀតឬ ។ ភិក្ខុពោលថា លោកម្ចាស់ដ៏ចម្រើន ឧទ្ទេសបូរលើកទុក លោកម្ចាស់ចូរប្រាប់កម្មដ្ឋានដល់ខ្ញុំ ឲ្យព្រះថេរៈប្រាប់កម្មដ្ឋានហើយ ជា

ព្រះសោតាបន្ន អាស្រ័យរៀនឧទ្ទេស ។ ជនសូម្បីពួកដទៃរៀរឧទ្ទេសក្នុងបទេសនេះ សម្រេចអរហត្ត មិនមានចំនួន (គណនានត្ថិ) ។ ក៏ព្រះសូត្រនេះ ព្រះពុទ្ធគ្រប់ព្រះអង្គ ទ្រង់មិនរៀរឡើយ (សព្វពុទ្ធានញ្ចេតំ សុត្តំ អវិជហិតមេវ ហោតិ) ។

បទថា ហីនកាយូបគា (បានកាយដ៏ថោកទាប) បានដល់ ជាអ្នកចូលដល់ពួកកាយដ៏ថោកទាប ។ បទថា ឧបាទានេ (ក្នុងឧបាទាន) គឺប្រកាន់ដោយតណ្ហា និងទិដ្ឋិ ។ បទថា ជាតិមរណសម្ភវេ (កើតឡើងនៃជាតិនិងមរណៈ) បានដល់ជាហេតុនៃការកើតឡើងនិងសេចក្តីស្លាប់ ។ បទថា អនុបាទា (ព្រោះមិនប្រកាន់មាំ) បានដល់ មិនប្រកាន់ដោយឧបាទាន ៤ ។ បទថា ជាតិមរណសង្ខយេ (អស់ទៅនៃជាតិនិងមរណៈ) គឺរមែងរួចផុត ព្រោះនិព្វាន ពោលគឺជាទីអស់ជាតិ និងមរណៈ ។

បទថា ទិដ្ឋធម្មាភិនិព្វុតា (រលត់កិលេសក្នុងបច្ចុប្បន្ន) សេចក្តីថា រលត់ហើយដោយសេចក្តីរលត់កិលេសទាំងពួង ក្នុងទិដ្ឋធម៌គឺ ក្នុងអត្តភាពនេះឯង ។ បទថា សព្វទុក្ខំ ឧបច្ចគុ (បានឆ្លងផុតទុក្ខទាំងពួង) គឺឈ្មោះថា កន្លងទុក្ខទាំងពួងបាន ។

ក្នុងអដ្ឋកថា មនោរថបូរណី លោកពន្យល់ថា ៖

បទថា សមនុយញ្ជតិ (សាកសួរ) សេចក្ដីថា យមរាជឲ្យនាំរបៀបក្នុងការសាកសួរ មកសាកសួរ ។ តែកាលឲ្យតាំងនៅទីនលទ្ធិ ឈ្មោះថា **ដេញដោលសួរ** ។ កាលសួរដល់ហេតុឈ្មោះថា **សួរឈ្វេចឈ្វី** ។

បទថា ជិណ្ណំ (ចាស់គ្រាំគ្រា) បានដល់ ទ្រុឌទ្រោមព្រោះជរា ។ បទថា គោបានសិវង្គំ (មានឆ្អឹងជំនីកោង) បានដល់ កោងដូចជាបង្កន់ផ្ទះ ។ បទថា ភោគ្គំ (មានកាយកោង) បានដល់ កាច់ចុះ ។ យមរាជសម្ដែងដល់ភាវៈដែលបុគ្គលនោះ (មានខ្នង) កោងនុ៎ះឯង ដោយបទថា **ភោគ្គំ** សូម្បីនេះ ។ បទថា ទណ្ឌបរាយនំ (កាន់ឈើច្រត់ដើរទៅ) គឺមានឈើច្រត់ជាទីពឹង បានដល់ មានឈើច្រត់ជាសម្ងាញ់ ។ បទថា បវេធមានំ (ញ័ររន្ធត់) បានដល់ ញ័រញ៉ៅ ។ បទថា អាតុរំ (ក្ដៅអន្ទះសា) បានដល់ រសាប់រសល់ព្រោះជរា ។ បទថា ខណ្ឌទន្តំ (មានធ្មេញបាក់) បានដល់ ឈ្មោះថា មានធ្មេញបាក់ ព្រោះអានុភាពរបស់ជរា ។ បទថា បលិតកេសំ

(មានសក់ស្កូវ) បានដល់ មានសក់ស ។ បទថា វិលូនំ (មានក្បាលឆក) បានដល់ ក្បាលទំពែក ដូចត្រូវអ្នកណាដកយកសក់ទៅ ។ បទថា ខលិតសិរំ (មានក្បាលទំពែក) បានដល់ ក្បាលទំពែក ច្រើន ។ បទថា វលិតំ (មានស្បែកជ្រួញជ្រីវ) បានដល់ កើតស្នាមជ្រួញជ្រីវ ។ បទថា តិលកាហាតគត្តំ (មានខ្លួនសៅហ្មងដោយប្រជ្រុយ) បានដល់ មានខ្លួនដាស់ទៅដោយអុជស អុជខ្មៅ ។

បទថា អាពាធិកំ (មានជម្ងឺ) បានដល់ ឈឺចាប់ ។ បទថា ទុក្ខិតំ (សេចក្ដីលំបាក) បានដល់ មានទុក្ខ ។ បទថា ពាឡ្ហគិលានំ (ឈឺធ្ងន់) បានដល់ ឈឺធ្ងន់លើសប្រមាណ ។

ក្នុងបទថា ឯកាហមតំ ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ : សត្វនោះស្លាប់បានមួយថ្ងៃ ព្រោះហេតុនោះទើបឈ្មោះថា **ឯកាហមត:** ។ (លោកមិនឃើញ) សត្វស្លាប់ក្នុងមួយថ្ងៃនោះ (ឬ) ។ សូម្បីក្នុងពីរបទតមក (គឺ **ទ្វីហមតំ វា តីហមតំ វា**) ក៏មានន័យនេះឯង ។ អសុកហើមប៉ោង ឈ្មោះថា ឧទ្ធុមាតកៈ ព្រោះឡើងប៉ោង ដោយការៈដែលហើមប៉ោងខ្ពស់

ឡើងតាមលំដាប់ រាប់តាំងពីអស់ជីវិតទៅ ដូចស្នប់ដែលពេញដោយខ្យល់ដូច្នោះ ។ សាកសពដែលមានពណ៌(ខៀវ) ឡើងទូទៅ ហៅថា **វិនីលៈ** វិនីលៈនោះឯង ឈ្មោះថា **វិនីលកៈ** ។ (លោកមិនឃើញ) សាកសពដែលខៀវស្រគាំនោះ (ឬ) ។ ម្យ៉ាងទៀត សាកសពដែលខៀវនោះ រាប់ថាគួរខ្ពើស ព្រោះជារបស់គួរខ្ពើម ។ បទថា វិបុព្វកំ បានដល់ សាកសពដែលមានទឹកលឿងហូរជ្រៀប ។ អធិប្បាយថា សាកសពដែលប្រឡាក់ប្រឡូសទៅដោយទឹកលឿង ដែលហូរចេញពីទីដែលបែកទូទៅ ។

## ការដាក់ទោសក្នុងនរក

បទថា តត្តំ អយោខិលំ (បោះដែកគោលដ៏ក្តៅ) សេចក្តីថា នាយនិរយបាលទាំងឡាយចាប់អត្តភាព (ខ្លួនធំ) ប្រមាណ ៣ គាវុត ឲ្យដេកផ្ងារ លើផែនដីលោហៈដែលភ្លើងឆេះសន្ធោសន្ធៅហើយយកលំពែងដែកខ្នាតប៉ុនដើមត្នោត ចាក់ចូលទៅត្រង់ដៃស្តាំ ត្រង់ដៃឆ្វេងជាដើម (ក៏ធ្វើ) ដូចគ្នា ។ នាយនិរយបាលទឹងចាប់សត្វនរកនោះឲ្យដេកផ្កាប់មុខខ្លះ ផ្អៀងឆ្វេងខ្លះ ផ្អៀងស្តាំខ្លះ ដូចឲ្យដេកផ្ងារហើយដាក់ទោសដូច្នោះដែរ ។

បទថា សំវេសេត្វា (ចាប់ផ្តេក) សេចក្តីថា (នាយ-និរយបាល) ចាប់អត្តភាពប្រមាណ ៣ គាវុតឲ្យដេកលើផែនដី-លោហៈ ដែលភ្លើងឆេះ សន្ធោសន្ធៅ ។ បទថា កុឋារីហិ (ដោយដឹង) សេចក្តីថា ចាំងដោយដឹងទាំងឡាយ ខ្នាតធំប៉ុនដំបូលផ្ទះផ្តេកម្ខាង, ឈាមហូរជោកជាស្ទឹង ។ អណ្តាតភ្លើងឆេះសន្ធោសន្ធៅអំពីផែនដីលោហៈ ទៅជាប់កន្លែងដែលត្រូវចាំង ។ ទុក្ខធំកើតឡើង (ដល់សត្វនរក) ចំណែកនាយនិរយបាលទាំងឡាយកាលចាំង ក៏ចាំងឲ្យជា ៨ ជ្រុងខ្លះ ៦ ជ្រុងខ្លះ ដូចវាយខ្សែបន្ទាត់ចាំងឈើ ។ បទថា វាសីហិ (ដោយកាំបិត) គឺដោយកាំបិតទាំងឡាយមានខ្នាតប៉ុនចង្អេរធំ ។

បទថា រថេ យោជេត្វា (ទឹមនឹងរថ) សេចក្តីថា (នាយនិរយបាលទាំងឡាយ) ទឹមសត្វនរកនោះឲ្យទាញរថព្រមជាមួយនឹងទឹម ខ្សែ ប្រែក កង់រថ កុព្វរ (ទូក) និងជន្ទួញដែលមានភ្លើងឆេះសន្ធោសន្ធៅជុំវិញផ្តេកខាង ។ បទថា មហាន្តំ (ដ៏ធំ) គឺមានប្រមាណប៉ុនផ្ទះកំពូលខ្នាតធំ ។

បទថា អារោបេន្តិ (ប្រើឲ្យឡើង) សេចក្តីថា វាយ

ដោយញញួរដែក ដែលភ្លើងឆេះសន្ធោសន្ធៅ ហើយបន្តាប់ឲ្យឡើង (ភ្នំរងើកភ្លើង) ។ បទថា សកិាបិ ឧទ្ធំ (អណ្តែតឡើងលើ) សេចក្តីថា សត្វនរកនោះ (ត្រូវភ្លើងដុតឆេះ) ឆ្អេរឆ្អាឡើងខាងលើ លិចចុះខាងក្រោម និងអណ្តែតទទឹង ដូចជាអង្ករដែលដាក់ចុះទៅក្នុងឆ្នាំងដែលក្តៅឆ្អេរឆ្អា ដូច្នោះ ។

បទថា មហានិរយេ (ក្នុងមហានរក) គឺក្នុងអវីចិមហានរក ។ បទថា ភាគសោ មិតោ (បែងចែកដោយចំណែកៗ) គឺ (មហានរក) បែងចែកទុកជាចំណែកៗ ។ បទថា បរិយន្តោ (ព័ន្ធព័ទ្ធជុំវិញ) គឺ ត្រូវលោមព័ទ្ធទុក ។ បទថា អយសា (គម្របដែក) គឺ ត្រូវបិទខាងលើដោយផែនដែក ។

បទថា សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ (ផ្សាយទៅបានមួយរយយោជន៍ជុំវិញ តាំងនៅសព្វៗកាល) សេចក្តីថា អណ្តាតភ្លើងផ្សាយទៅតាំងនៅយ៉ាងនោះ ។ កាលសត្វនរកនោះឈរមើលនៅក្នុងទី ១០០ យោជន៍ ដោយជុំវិញ ភ្នែកក៏នឹងចេញមកដូចដុំសាច់ ២ ដុំ ដូច្នោះ ។

ចប់ អដ្ឋកថា ទេវទូតសូត្រ ។

# II. អំពីប្រេតទាំងឡាយ

## ១.អដ្ឋិសង្ខលិក

សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះឯង ព្រះលក្ខណៈមានអាយុ និងព្រះមហាមោគ្គល្លានមានអាយុ គង់នៅនាភ្នំគិជ្ឈកូដ ។

គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅរកព្រះលក្ខណៈមានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះលក្ខណៈមានអាយុថា ម្នាលអាវុសោលក្ខណៈ អ្នកចូរមក យើងនឹងចូលទៅក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះលក្ខណៈមានអាយុ ទទួលពាក្យព្រះមហាមោគ្គល្លានមានអាយុថា អើអាវុសោ ។ គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ កាលនិមន្តចុះអំពីភ្នំគិជ្ឈកូដ ក៏ធ្វើនូវការញញឹមឲ្យប្រាកដក្នុងប្រទេសមួយ ។ គ្រានោះឯង ព្រះលក្ខណៈមានអាយុ បានសួរព្រះមហាមោគ្គល្លានមានអាយុ ដូច្នេះថា ម្នាលអាវុសោ មោគ្គល្លាន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាលោកធ្វើនូវការ

ញញឹមឲ្យប្រាកដ ។ ម្នាលអាវុសោលក្ខណៈ កាលនេះ ជាកាលមិនគួរដើម្បីសួរប្រស្នានេះទេ អ្នកចូរសួរប្រស្នានេះនឹងខ្ញុំក្នុងសំណាក់ព្រះមានព្រះភាគចុះ ។

គ្រានោះឯង ព្រះលក្ខណៈមានអាយុ និងព្រះមហាមោគ្គ-ល្លានមានអាយុ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះលក្ខណៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានសួរព្រះមហាមោគ្គល្លានមានអាយុថា ក្នុងទីឯណោះ មហាមោគ្គល្លានមានអាយុ កាលចុះមកអំពីភ្នំគិជ្ឈកូដ បានធ្វើនូវការញញឹមឲ្យប្រាកដក្នុងប្រទេសមួយ ម្នាលអាវុសោមោគ្គល្លាន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាលោកធ្វើនូវការញញឹមឲ្យប្រាកដ ។

ព្រះមហាមោគ្គល្លានតបថា ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញ**អដ្ឋិកសង្ខលិក** គឺឆ្អឹង កំពុងអណ្តែតទៅក្នុងអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាបចោមចឹកចោះ ភើចជញ្ជែងនូវរាងឆ្អឹងនោះ រាងឆ្អឹងនោះ

ក៏ចេះតែស្រែកថ្ងូរ ម្នាលអាវុសោ ទើបខ្ញុំនោះ មានសេចក្តីបរិវិតក្កៈថា យីអើ អស្ចារ្យណាស់ យីអើ មិនធ្លាប់កើតមានសោះឡើយ យីអើ សត្វបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរ យក្ខបែបនេះ នឹងត្រឡប់ជាមានខ្លះដែរ កិរិយាបានអត្តភាពបែបនេះ នឹងត្រឡប់ទៅជាមានខ្លះដែរតើ ។

គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានញាណកើតពិតហើយ ដ្បិតសាវ័កដឹង ឬឃើញសត្វបែបនេះ ឬបានឹងធ្វើសត្វបែបនេះឲ្យជាសាក្សី (ដល់តថាគតបាន) ។ ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតធ្លាប់ឃើញមកអំពីមុនដែរ ប៉ុន្តែតថាគតមិនទាន់សម្តែង បើតថាគតសម្តែងអំពីរឿងសត្វនុ៎ះទៅ ជនទាំងឡាយដទៃមិនជឿពាក្យតថាគតទេ ជនទាំងឡាយណាមិនជឿពាក្យតថាគត សេចក្តីមិនជឿនោះ របស់ជនទាំងនោះ នឹងនាំឲ្យខានបានប្រយោជន៍ នាំឲ្យបានតែសេចក្តីទុក្ខអស់កាលជាយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ សត្វនោះ (ពីដើម) **ជាគោឃាតកៈ** គឺអ្នកសម្លាប់គោ ក្នុងក្រុងរាជគ្រឹះនេះឯង ដោយវិបាករបស់កម្មនោះ គោឃាតកៈ

បុរសនោះ ក៏ទៅឆេះក្នុងនរកអស់ឆ្នាំដ៏ច្រើន អស់រយឆ្នាំដ៏ច្រើន អស់ពាន់ឆ្នាំដ៏ច្រើន អស់សែនឆ្នាំដ៏ច្រើន ដោយសេសសល់វិបាកនៃកម្មនោះឯង ទើបបានត្រឡប់មកទទួលផល គឺត្រឡប់បានអត្តភាពបែបនេះឯង ។

## ភ្លេងអដ្ឋកថាពន្យល់ថា

ព្រះលក្ខណត្ថេរ ដែលព្រះធម្មសង្គាហកាចារ្យ ពោលទុកក្នុងលក្ខណសំយុត្តថា **អាយស្មា ច លក្ខណោ** ជាដើមនេះ បណ្ឌិតគប្បីជ្រាបថា មាននៅក្នុងបណ្ដាភិក្ខុជដិលមួយពាន់រូបឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា បានសម្រេចជាព្រះ-អរហន្ត ក្នុងទីបំផុតនៃអាទិត្តបរិយាយសូត្រ ជាព្រះមហាសាវកមួយរូប ។ ក៏ព្រោះព្រះថេរៈអង្គនេះ ប្រកបដោយអត្តភាពដូចព្រហ្ម បរិបូរណ៍ដោយលក្ខណៈ ពេញដោយអាការគ្រប់យ៉ាង; ដូច្នោះ ទើបលោកដល់ការរាប់ថា **លក្ខណៈ** ចំណែកព្រះមហា-មោគ្គល្លានត្ថេរ ជាព្រះអគ្គសាវកទី ២ បានសម្រេចជាព្រះ-អរហន្ត ក្នុងថ្ងៃទី ៧ ក្រោយពីថ្ងៃដែលព្រះថេរៈបួសហើយ ។

ពីរបទថា **សិតំ បាត្វាកាសិ** (ធ្វើការញញឹមឲ្យប្រាកដ)

សេចក្តីថា ព្រះមហាមោគ្គល្លានត្ថេរ បានធ្វើការញញឹមតិចៗឲ្យប្រាកដ ។ មានពាក្យអធិប្បាយថា ប្រកាស គឺសម្តែង ។

សួរថា ក៏ព្រះថេរៈឃើញអ្វី ទើបបានធ្វើការញញឹមឲ្យប្រាកដ ? ឆ្លើយថា ព្រះថេរៈឃើញសត្វដែលកើតនៅក្នុងបេត-លោកមួយ មានតែរាងឆ្អឹងដែលមកហើយក្នុងបាលីខាងមុខ, ក៏ឯការឃើញសត្វនោះ ឃើញបានដោយទិព្វចក្ខុ មិនមែនឃើញដោយចក្ខុប្រសាទទេ ។ ពិតមែន អត្តភាពទាំងនោះ មិនបាន-មកកាន់គន្លងនៃចក្ខុប្រសាទទេ ។

សួរថា ក៏ព្រះថេរៈឃើញអត្តភាពមានរូបយ៉ាងនោះហើយព្រោះហេតុអ្វី ទើបបានធ្វើការញញឹមឲ្យប្រាកដ ក្នុងកាលគួរធ្វើសេចក្តីករុណាហ្ន៎ ?

ឆ្លើយថា ព្រោះព្រះថេរៈរលឹកដល់សម្បត្តិរបស់ខ្លួន និងព្រះញាណរបស់ព្រះពុទ្ធផង ។ ពិតមែន ព្រះថេរៈឃើញប្រេតនោះហើយ បានរលឹកដល់សម្បត្តិរបស់ខ្លួនថា “អត្តភាពបែបនេះដែលបុគ្គលឈ្មោះថា មិនទាន់ឃើញសច្ចៈនឹងគប្បីបាន, យើងផុតហើយចាកអត្តភាពដូច្នោះ, ជាលាភរបស់យើង យើងបានល្អហើយហ្ន៎” និងបានរលឹកដល់សម្បត្តិនៃព្រះពុទ្ធញាណ យ៉ាងនេះ

ថា "ញាណសម្បត្តិរបស់ព្រះមានព្រះភាគ ដែលទ្រង់សម្តែងថា (ម្នាលភិក្ខុទាំងឡាយ វិបាករបស់កម្មជាអចិន្តេយ្យ ដែលបុគ្គលមិនគួរគិត) គួរអស្ចារ្យ, ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងសម្តែងធ្វើឲ្យប្រចក្សហ្ន៎ ធម្មធាតុដែលព្រះពុទ្ធទាំងឡាយ ទ្រង់ចាក់ធ្លុះល្អហើយ" ដូច្នេះ ទើបបានធ្វើការញញឹមឲ្យប្រាកដ ។

ក៏ធម្មតាថា ព្រះខីណាស្រពទាំងឡាយ មិនធ្វើការញញឹមឲ្យប្រាកដ ព្រោះមិនមានហេតុ; ព្រោះដូច្នោះ ទើបព្រះលក្ខណត្ថេរ សួរព្រះមហាមោគ្គល្លានត្ថេរ នោះថា "ម្នាលអាវុសោមោគ្គល្លាន អ្វីជាហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវការញញឹមឲ្យប្រាកដ (នេះ)" តែព្រះថេរៈឆ្លើយតបថា "ម្នាលអាវុសោលក្ខណៈ កាលនេះ មិនមែនជាកាលគួរព្យាករណ៍ប្រស្នានេះទេ លោកចូរសួរប្រស្នានេះនឹងខ្ញុំ ក្នុងសំណាក់ព្រះមានព្រះភាគចុះ"។ ដោយហេតុដែលលោកមានសេចក្តីប្រាថ្នា នឹងឲ្យព្រះមានព្រះភាគ ជាសាក្សីជាមុនសិន ទើបព្យាករណ៍ ព្រោះហេតុថា ភិក្ខុទាំងឡាយ អ្នកដែលមិនបានឃើញការឧប្បត្តិឡើងនេះដោយខ្លួនឯងហើយ នឹងបន្ទាប់ឲ្យជឿបានដោយលំបាក ។ ខាងក្រោយអំពីនោះ ព្រះមហាមោគ្គល្លានត្ថេរ ត្រូវព្រះលក្ខណត្ថេរ សួរក្នុង

សំណាក់ព្រះមានព្រះភាគ ទើបបានព្យាករណ៍ដោយន័យមាន ជាដើមថា **ឥធាហំ អាវុសោ** ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋិកសង្ខលិកំ** (ប្រេតមានឆ្អឹងពណ៌សង្ខ) បានដល់ ប្រេតមានតែរាងឆ្អឹងដែលមានពណ៌ស មិនមានសាច់និងឈាម ។ ត្មាតយក្ខ ខ្លែងយក្ខ និងរអាតយក្ខ សូម្បីទាំងនេះ គប្បីជ្រាបថា ត្មាតខ្លះ ខ្លែងខ្លះ និងរអាតខ្លះ ។ ក៏រូបនោះ មិនមកសូម្បីកាន់គន្លង (នៃចក្ខុ) របស់ហ្វូងត្មាត ជាដើមតាមប្រក្រតី ។

ពីរបទថា **អនុបតិត្វា អនុបតិត្វា** បានដល់ នាំគ្នាដេញតាមទៅហើយៗ ។ បទថា **វិតុទេន្តិ** បានដល់ ចឹកហើយហើរទៅ ។ម្យ៉ាងទៀត បាលីថា **វិតុទន្តិ** ក៏មាន ។ អធិប្បាយថា រមែងចឹកដោយចុងចំពុះលោហៈដ៏មុតដូចជាមុខដាវ ។ ស័ព្ទថា **សុទំ** ក្នុងពាក្យថា **សា សុទំ អដ្ដស្សរំ ករោតិ** (ប្រេតនោះ ចេះតែស្រែកថ្ងូរ) នេះ ជានិបាត ។ អធិប្បាយថា អដ្ឋិកសង្ខលិក- ប្រេតនោះ រមែងធ្វើសំឡេងស្រែកថ្ងូរ គឺសំឡេងយំ ។ បានឮថា អត្តភាពដូច្នោះ សូម្បីមានប្រមាណមួយយោជន៍ រមែងកើតឡើង និងមានប្រសាទដែលប៉ោងឡើង ដូចបូសដែលទុំហើយ

ដើម្បីតាមសោយផលនៃអកុសល ព្រោះដូច្នោះ អដ្ឋិកសង្ខ-លិកប្រេតនោះ ក្តៅក្រហាយព្រោះវេទនាដ៏មានកម្លាំង ទើបបាន ធ្វើសំឡេងដូច្នោះឯង ។

លុះព្រះមហាមោគ្គល្លានពោលយ៉ាងនេះហើយ កាលនឹង សម្តែងធម្មសង្វេគទៀតដែលកើតឡើង ព្រោះអាស្រ័យសេចក្តី ករុណាក្នុងសត្វទាំងឡាយថា ដែលឈ្មោះថា សត្វទាំងឡាយ អ្នកទៅក្នុងវដ្ដៈ រមែងមិនផុតពីអត្តភាពបែបនេះទៅបាន ទើប ពោលពាក្យជាដើមថា "ម្នាលអាវុសោ ទើបខ្ញុំបានបរិវិតក្កៈថា យីអើហ្ន៎ (នេះហៅពេញ) ជាអស្ចារ្យ យីអើហ្ន៎ មិនធ្លាប់កើត មានសោះឡើយ" ដូច្នេះ ។

ពីរបទថា **ភិក្ខូ ឧជ្ឈាយន្តិ** (ភិក្ខុទាំងឡាយ ទើបពោល ទោស) សេចក្តីថា សេចក្តីឧប្បត្តិឡើងនៃប្រេតនោះ មិនឃើញ ប្រចក្សដល់ភិក្ខុពួកណា, ភិក្ខុទាំងនោះ នាំគ្នាពោលទោស ។ ចំណែកព្រះមានព្រះភាគ កាលនឹងទ្រង់ប្រកាសអានុភាពរបស់ ព្រះថេរៈ ទើបត្រាស់ព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សាវ័ក ទាំងឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវ័ក ទាំងឡាយ មានញាណកើតពិតហើយ ព្រោះហេតុថា សាវ័កនឹង

ដឹង ឬនឹងឃើញប្រេតបែបនេះ ឬថា នឹងធ្វើប្រេតបែបនេះ ឲ្យជាបន្ទាល់(របស់តថាគត) ម្នាលភិក្ខុទាំងឡាយសត្វនោះតថាគត-បានឃើញក្នុងកាលមុនរួចមកហើយ ប៉ុន្តែតថាគត មិនបានសម្តែង ព្រោះថា តថាគតសម្តែងទៅ ពពួកជនដទៃមិនជឿ(ពាក្យ) តថាគត ពពួកជនណាដែលមិនជឿតថាគត សេចក្តីដែលមិនជឿនោះ នឹងនាំឲ្យខានបានប្រយោជន៍ នាំឲ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ពពួកជននោះ ម្នាលភិក្ខុទាំងឡាយសត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតគោក្នុងក្រុងរាជគ្រឹះនេះឯងដោយកម្មវិបាកនោះ អ្នកពិឃាតគោនោះ ទៅឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយពាន់សែនឆ្នាំដ៏ច្រើន, ដោយវិបាកនៃកម្មនោះនៅសេសសល់ ក៏ត្រឡប់មកទទួលផល គឺត្រឡប់បាននូវអត្តភាពបែបនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លាន មិនត្រូវអាបត្តិទេ” ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សាវកទាំងឡាយ មានចក្ខុកើតពិតហើយ** ព្រោះអត្ថថា សាវកទាំងនោះមានចក្ខុប្រាកដហើយ កើតហើយ ឧប្បត្តិហើយ ។ សេចក្តីថា ជាអ្នកមានចក្ខុ

ប្រាកដហើយ គឺមានចក្ខុកើតហើយ ញុំាងចក្ខុឲ្យកើតឡើង ហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ពាក្យថា **យត្រ** ដែលមាននៅក្នុងពាក្យថា **យត្រ ហិ នាម** នេះ ជាពាក្យបញ្ជាក់ ដល់ហេតុ ។ ក្នុងពាក្យថា **ចក្ខុភូតា** ជាដើមនោះ មានការ ប្រកបសេចក្ដីដូចតទៅនេះ ព្រោះហេតុថា សូម្បីសាវកនឹងដឹង ឬនឹងឃើញ ឬនឹងធ្វើអត្តភាពបែបនេះ ឲ្យជាសាក្សីបាន; ដូច្នោះ ទើបតថាគតបានពោលថា "ម្នាលភិក្ខុទាំងឡាយ សាវកទាំង-ឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវក ទាំងឡាយ មានញាណកើតពិតហើយ" ដូច្នេះ ។

ពាក្យថា **បុព្វេ វ មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ** (ម្នាលភិក្ខុទាំងឡាយ សត្វនោះ តថាគតបានឃើញពីក្នុងកាល-មុនរួចមកហើយ) មានសេចក្ដីថា (ព្រះមានព្រះភាគ) ត្រាស់ថា តថាគតបានចាក់ធ្លុះសព្វញ្ញុតញ្ញាណទៀបពោធិមណ្ឌល ធ្វើពួក-សត្វ និងភព គតិ ឋិតិ និងនិវាស មិនមានប្រមាណ ក្នុង ចក្កវាឡទាំងឡាយ មិនមានប្រមាណឲ្យប្រចក្ស បានឃើញសត្វ នោះហើយក្នុងកាលមុន ។

បទថា **គោឃាតកោ** (ជាអ្នកពិឃាតគោ) សេចក្ដីថា ជា

អ្នកសម្លាប់គោទាំងឡាយហើយ ពន្លះសាច់ចេញពីឆ្អឹង លក់-ចិញ្ចឹមជីវិត ។ ច្រើនបទថា **តស្សេវ កម្មស្ស វិបាកាវសេសេន** (ដោយសេសសល់នៃកម្មវិបាកនោះ) សេចក្ដីថា នៃអបរាបរ-វេទនីយកម្មដែលចេតនាផ្សេងៗ ប្រមូលមកហើយនោះឯង ។ ពិតមែន បណ្ដាចេតនាទាំងនោះ បដិសន្ធិក្នុងនរកដោយចេតនាណាឲ្យកើតឡើង ហើយកាលវិបាកនៃចេតនាដូងនោះ អស់ទៅហើយ, បដិសន្ធិក្នុងប្រេតជាដើម រមែងកើតទៀត; ព្រោះធ្វើកម្មដ៏សេស ឬកម្មនិមិត្តឲ្យជាអារម្មណ៍ ព្រោះហេតុនោះ បដិសន្ធិនោះ ទើបលោកហៅថា វិបាកដ៏សេសនៃកម្មនោះឯង ព្រោះមានចំណែកស្មើដោយកម្ម ឬព្រោះមានចំណែកស្មើដោយអារម្មណ៍ ។ ក៏សត្វនេះកើតឡើងហើយយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា "ដោយសេសសល់នៃកម្មវិបាកនោះ" ។ បានឮថា ក្នុងកាលរួចផុតពីនរក សត្វនោះបានមាននិមិត្ត គឺគ្រោងឆ្អឹងនៃគោទាំងឡាយ ដែលត្រូវធ្វើ មិនឲ្យមានសាច់, សត្វនោះ កាលនឹងធ្វើកម្មនោះសូម្បីដែលបិទបាំងឲ្យដូចជាប្រាកដដល់វិញ្ញូជនទាំងឡាយ ទើបកើតជាអដ្ឋិកសង្ខលិកប្រេត ។

# ២.មំសបេសិប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញមំសបេសិ គឺចម្រៀកសាច់ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ កើចជញ្ជែងនូវចម្រៀកសាច់នោះ ចម្រៀកសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាគោឃាតកៈ គឺអ្នកសម្លាប់គោ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

អដ្ឋកថា មំសបេសិប្រេតនោះ ជាអ្នកសម្លាប់គោ ធ្វើបន្ទះសាច់ហាលឲ្យក្រៀមហើយ ចិញ្ចឹមជីវិតដោយការលក់សាច់ក្រៀមច្រើនឆ្នាំ ។ ព្រោះហេតុនោះ កាលរួចផុតពីនរកគេទើបបានមាននិមិត្ត គឺបន្ទះសាច់នុ៎ះឯង គេទើបកើតជាមំសបេសិប្រេត ។

## ៣. មំសបិណ្ឌប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញមំសបិណ្ឌៈ គឺដុំសាច់កំពុងអណ្ដែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹក ចោះភើចជញ្ជែងនូវដុំសាច់នោះ ដុំសាច់នោះ ក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាព្រានបក្សី (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> មំសបិណ្ឌប្រេតនោះ ជាព្រានសត្វ ចាប់សត្វបានហើយ វេលាលក់ បានធ្វើការដករោមស្លាបនិងស្បែកចេញអស់ឲ្យនៅត្រឹមតែជាដុំសាច់ហើយ លក់ចិញ្ចឹមជីវិត ។ ព្រោះហេតុនោះ កាលរួចផុតពីនរក គេទើបបានមាននិមិត្ត គឺដុំសាច់ប៉ុណ្ណោះ ។ គេទើបកើតជាមំសបិណ្ឌប្រេត ។

## ៤. និច្ឆវីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញនិច្ឆវិបុរស មិនមានស្បែកក្រៅ កំពុងអណ្ដែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញ តាមឆាប

ចោមចឹកចោះ កើចជញ្ជែងនូវនិច្ឆវិបុរសនោះ និច្ឆវិបុរសនោះ ក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្លាប់ចៀម (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

អដ្ឋកថា និច្ឆវីប្រេតនោះ ជាអ្នកសម្លាប់ចៀមហើយបក-ស្បែកចិញ្ចឹមជីវិត ទើបបានមាននិមិត្ត គឺរាងកាយចៀមប្រាស-ចាកស្បែកតាមន័យមុននុ៎ះឯង គេទើបបានកើតជានិច្ឆវីប្រេត ។

## ៥_អសិលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដបានឃើញអសិលោមបុរស គឺបុរសមានរោមដូចដាវកំពុងអណ្តែតទៅលើអាកាស ដាវទាំងនោះ របស់បុរសនោះអណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកសម្លាប់ជ្រូក (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

អដ្ឋកថា អសិលោមប្រេតនោះ ជាអ្នកសម្លាប់ជ្រូក ប្រើ

ជាវសម្លាប់ជ្រូកទាំងឡាយ ដែលខ្លួនបំប៉នដោយចំណីអស់កាលយូរ ហើយចិញ្ចឹមជីវិតមករហូតអស់រាត្រីយូរ ។ គេទើបបានមាននិមិត្ត គឺការៈរបស់អ្នកដែលធាជាវឡើង ដូច្នោះ គេទើបកើតជាអសិលោមប្រេត ។

## ៦.សត្តិលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសត្តិលោមបុរស គឺបុរសមានរោមដូចជាលំពែង កំពុងអណ្តែតទៅលើអាកាស លំពែងទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯងបុរសនោះក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាព្រានម្រឹគ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> សត្តិលោមប្រេតនោះ ជាអ្នកបាញ់ម្រឹគ នាំយកម្រឹគមួយ និងកាន់លំពែងមួយ ទៅព្រៃហើយប្រើលំពែងចាក់ម្រឹគដែលនាំគ្នាមកកាន់ទីជិតម្រឹគនោះឲ្យស្លាប់ ។ គេទើបបានមាននិមិត្ត គឺការៈដែលប្រើលំពែងចាក់ ។ ដូច្នោះ គេទើបកើតជាសត្តិលោមប្រេត ។

# ៧.ឧសុលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញឧសុលោមបុរស គឺបុរសមានរោមដូចព្រួញកំពុងអណ្តែតទៅលើអាកាស ព្រួញទាំងនោះ របស់បុរសនោះអណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏បេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាពេជ្ឈឃាដ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> បទថា **ការណិកោ** (ជាពេជ្ឈឃាត) សេចក្តីថាជាបុរសអ្នកបៀតបៀនពួកមនុស្ស ដែលខុសចំពោះព្រះរាជាដោយហេតុទាំងឡាយជាច្រើន ចុងក្រោយក៏ប្រើកូនសរបាញ់ឲ្យស្លាប់ ។ បានឮថា គេជ្រាបមុនថា អ្នកត្រូវបាញ់ចំណែកឯណោះ ទើបនឹងស្លាប់ ដូច្នេះ ហើយទើបបាញ់ ។ គេនុ៎ះឯងចិញ្ចឹមជីវិតហើយកើតក្នុងនរក ក្នុងវេលាកើតក្នុងប្រេតវិស័យនេះបានមាននិមិត្ត គឺការៈដែលប្រើសរបាញ់ ដោយវិបាកដ៏សេសពីនរកនោះ ។ ដូច្នោះ គេទើបកើតជាឧសុលោមប្រេត ។

## ៨.សូចិលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសូចិលោមបុរស គឺបុរសមានរោមដូចដែកស្រួចកំពុងអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ៗ មកត្រូវកាយរបស់បុរសនោះវិញ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកបរគោ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> បទថា **សារថិ** (នាយសារថី) គឺជាអ្នកទូន្មានសេះ ។ ក្នុងអដ្ឋកថាកុរុន្ទី លោកពោលថា ជាអ្នកបង្ហឹកគោដូច្នេះខ្លះ ។ គេបានមាននិមិត្ត គឺភាវៈដែលចាក់ដោយជន្លួញ ។ គេទើបកើតជាសូចិលោមប្រេត ។

## ៩.សូចិលោមបុរស

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសូចិលោមបុរស គឺបុរសមានរោមដូចដែក-ស្រួច កំពុងអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះ របស់

បុរសនោះ ក៏ដោតចូលទៅក្នុងក្បាល ធ្លាយចេញមកតាមមាត់ ដោតចូលទៅក្នុងមាត់ធ្លាយចេញមកតាមទ្រូង ដោតចូលទៅក្នុងទ្រូងធ្លាយចេញមកតាមពោះ ដោតចូលទៅក្នុងពោះ ធ្លាយចេញមកតាមភ្លៅ ដោតចូលទៅក្នុងភ្លៅ ធ្លាយចេញមកតាមស្មង ដោតចូលទៅក្នុងស្មងធ្លាយចេញមកតាមបាតជើង បុរសនោះ ក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកចាក់ដោត ញុះញង់គេ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

អដ្ឋកថា បទថា **សូចិកោ** (ជាអ្នកញុះញង់គេ) គឺជាអ្នកធ្វើការស៊ិកសៀត ។ បានឮថា គេទំលាយមនុស្សទាំងឡាយនិងពួករួមគ្នា និងញុះញង់ក្នុងរាជត្រកូលថា "អ្នកនេះមានសេចក្ដីខុសឈ្មោះនេះ អ្នកនេះធ្វើខុសឈ្មោះនេះ" ដូច្នេះ, គ្រាញុះញង់ហើយ ធ្វើឲ្យដល់សេចក្ដីវិនាសអស់ ។ ដូច្នោះ គេទើបកើតជាសូចិលោមប្រេត ព្រោះធ្វើនិមិត្ត គឺកម្ម ដើម្បីការសោយទុក្ខអំពីការទម្លាយដោយស្នៀតទាំងឡាយ ដូចដែលគេស៊ិកសៀតបំបែកពួកមនុស្ស ដូច្នោះ ។

# ១០~គុម្ភណ្ឌប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញកុម្ភណ្ឌបុរស គឺបុរសមានអណ្ឌៈប៉ុនក្អមកំពុងអណ្ដែតលើអាកាស កាលបុរសនោះដើរទៅ លុះតែលើកអណ្ឌៈទាំងនោះដាក់ត្រង់ក(ឈើ) ទើបទៅបាន កាលអង្គុយក៏អង្គុយសង្កត់លើអណ្ឌៈទាំងនោះឯង ពួកត្មាត ក្អែក រអាតដេញតាមឆាប ចោមចឹកចោះ ភើចជញ្ជែងនូវបុរសនោះ បុរសនោះ ក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកកាន់អំពើវៀចក្នុងស្រុក (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> បទថា **គាមកូដោ** (ជាអាមាត្យអ្នកវិនិច្ឆ័យក្តីនៃអ្នកស្រុកដោយអំពើវៀច) គឺជាអាមាត្យអ្នកកាត់ក្តីបណ្តឹង ។ សត្វនោះបានមានអណ្ឌៈប៉ុនឆ្នាំង គឺមានខ្វាតប៉ុនឆ្នាំងធំ ព្រោះមានចំណែកស្មើដោយកម្ម ។ ព្រោះថា សត្វនោះ ព្រោះហេតុដែលទទួលសំណូកក្នុងស្ថានទីកំបាំង កាលនឹងធ្វើទោសឲ្យប្រាកដដោយការកាត់ក្តីបណ្តឹងកោង បានធ្វើពួកម្ចាស់របស់ មិនឲ្យជាម្ចាស់របស់; ព្រោះដូច្នោះ អវយវៈកំបាំងរបស់សត្វនោះ ទើប

កើតប្រាកដ ។ ព្រោះហេតុដែលសត្វនោះ កាលចាប់ដើមតាំងអាជ្ញា បានលើករបស់ធ្ងន់ដែលមិនគួរនឹងធន់បាន ឲ្យដល់ជនពួកដទៃ; ព្រោះហេតុដែលសត្វនោះតាំងនៅក្នុងតំណែងណា គួរនឹងជាអ្នកស្មើ, តែតាំងនៅក្នុងតំណែងនោះហើយមិនបានជាអ្នកស្មើទេ; ដូច្នោះ សត្វនោះទើបបានមានការអន្ទ្រុយមិនរៀបរយ គឺអន្ទ្រុយលើអវយវៈកំបាំង ។

## ១១_រឿងបរទារិកប្រេត

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញបុរសម្នាក់ កំពុងមុជចុះទៅក្នុងរណ្តៅលាមក ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះជាអ្នកប្រព្រឹត្ត**បរទារិកកម្ម** គឺលួចប្រពន្ធអ្នកដទៃ (ពីដើម) ក្នុងក្រុងរាជគ្រឹះនេះឯង ។

(បេយ្យាលបណ្ឌិតគប្បីធ្វើយ៉ាងនេះ)

<u>អដ្ឋកថា</u> : សត្វនោះ កាលប៉ះពាល់សម្ផស្សដែលមានម្ចាស់គេឃុំគ្រងរក្សាហើយរបស់អ្នកដទៃ ញុំាងចិត្តឲ្យរីករាយ

ដោយសេចក្ដីសុខក្នុងកាម ដែលជាសេចក្ដីសុខក្នុងឧច្ចារៈ ទើបកើតក្នុងប្រេតវិស័យនោះ ដើម្បីនឹងប៉ះពាល់សម្ផស្សជាលាមកសោយទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

## ១២_រឿងព្រាហ្មណ៍កំណាច

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញបុរសម្នាក់ កំពុងមុជចុះក្នុងរណ្ដៅលាមក ចាប់លាមកដោយដៃទាំងសងខាងស៊ី ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះពីដើមជាព្រាហ្មណ៍ ក្នុងក្រុងរាជគ្រឹះនេះឯង ។ ព្រាហ្មណ៍នោះ កាលក្នុងសាសនាព្រះ-កស្សបសម្មាសម្ពុទ្ធ បាននិមន្តភិក្ខុសង្ឃដោយភត្តាហារ ក៏ដាក់លាមកពេញក្នុងស្នូក រួចហើយប្រើគេឲ្យប្រាប់កត្តកាល ហើយពោលដូច្នេះថា សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ជរាបដល់ឆ្អែតផង សូមនិមន្តយកទៅផង ។

# ១៣~រឿងនិច្ចវិប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញស្រីនិច្ចវី គឺស្រីមិនមានស្បែកក្រៅ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាបចោមចឹកចោះ កើចជញ្ជែង នូវស្រីនោះ ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (ពីដើម) ជាស្រីប្រព្រឹត្តកន្លងចិត្តប្តី ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> : ព្រោះឈ្មោះថា មាតុគ្រាម មិនជាឥស្សរៈក្នុងផស្សៈរបស់ខ្លួន ។ តែស្រីនោះលួចផស្សៈរបស់ស្វាមីនោះញ៉ាំងសេចក្តីអភិរម្យឲ្យកើតដល់ពួកជនដទៃ; ដូច្នោះ ទើបបានកើតជាស្រីប្រេតប្រាសចាកសម្បុរស្បែក ដើម្បីកម្ចាត់សម្ផស្សជាសុខចេញទៅហើយ សោយសម្ផស្សជាទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

# ១៤-រឿងមង្គុលិស្ត្រីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញស្រីមង្គុលី មានក្លិនស្អុយ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ កើចជញ្ជែងនូវស្រីនោះ ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (ពីដើម) ជាស្រីមេមត់ ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> : បទថា **មង្គុលី** (ប្រេតអាក្រក់ គួរខ្ពើមឆ្អើម) បានដល់ មានរូបខុសប្រក្រតីទៅ គឺសម្លឹងមើលគួរស្អប់គួរខ្ពើម ។ បានឮថា ស្រីនោះធ្វើនាទីជាមេមត់ គឺជាប្រធាន-ទាសីរបស់យក្ខ ពោលថា "កាលធ្វើពលីកម្មយ៉ាងនេះ ដោយវត្ថុនេះនិងវត្ថុនេះ សេចក្តីចម្រើនរបស់ពួកលោក ឈ្មោះនេះនឹងមាន" ដូច្នេះ ហើយកាន់យករបស់ក្រអូប និងផ្កាឈើជាដើមរបស់មហាជន ដោយការបោកបញ្ឆោត ញ៉ាំងមហាជនឲ្យប្រកាន់មិច្ឆាទិដ្ឋិ ដែលជាទិដ្ឋិអាក្រក់ ។ ព្រោះដូច្នោះ ទើបនាងកើតជាស្រីប្រេតមានក្លិនស្អុយ ព្រោះលួចរបស់ក្រអូប និងផ្កា-ឈើជាដើម ជាស្រីប្រេតសម្លឹងមើលគួរស្អប់ មានរូបអាក្រក់

គួរខ្លើម ព្រោះហេតុឲ្យមហាជនប្រកាន់សេចក្ដីអាក្រក់ ព្រោះមានចំណែកស្មើដោយកម្មនោះ ។

## ១៥-រឿងឱកិលិនីស្រីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញស្រីមានកាយឆេះរោលរាលដោយភ្លើង មានកាយសើមជោគជាំ មានកាយដេរដាសដោយរងើកភ្លើង កំពុងតែអណ្ដែតទៅលើអាកាស ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ ស្រីនុ៎ះ (ពីដើម) ជាអគ្គមហេសី នៃស្ដេចក្នុងដែនកលិង្គ ស្រីនោះ ជាអ្នកមានសេចក្ដីឫស្យាគ្របសង្កត់ បានចាក់រងើកភ្លើងមួយអំបែងលើស្រីជាមហេសីចុង ។

អដ្ឋកថា ពាក្យថា **ឧប្បក្កំ ឱកិលិំ ឱកីរណិំ** (ដែលកើតជាឱកិលិនីប្រេត ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើង ធ្លាក់ស្រោចលើខ្លួន) មានសេចក្ដីថា បានឮថា ស្រីប្រេតនោះ ដេកនៅលើជើងថ្ករងើកភ្លើង បម្រះនទៀលត្រឡប់ទៅមក ត្រូវភ្លើងឆេះ; ព្រោះដូច្នោះ នាងទើបជាអ្នកត្រូវភ្លើងឆេះរោលរាល មានសរីរៈឆ្អិនដោយភ្លើងក្រុត មានទឹកញើសស្រក់ មានសរីរៈសើម

គឺតំណក់ទឹកញើសទាំងឡាយ រមែងហូរចេញអំពីសរីរៈ របស់ស្រីប្រេតនោះ និងមានរងើកភ្លើងដេរដាស់ គឺពាសពេញដោយរងើកភ្លើង ។ ព្រោះថា រងើកភ្លើងទាំងឡាយ មានពណ៌ដូចផ្កាល្ហុសផ្អុង រមែងធ្លាក់សូម្បីអំពីខាងក្រោមរបស់ស្រីប្រេតនោះ រងើកភ្លើងទាំងឡាយ រមែងធ្លាក់ទាំងសងខាង សូម្បីអំពីអាកាសក្នុងខាងលើរបស់ស្រីប្រេតនោះ ។ ដោយហេតុនោះ លោកទើបពោលថា "ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន ទឹកញើសស្រក់ (ក្ដៅអន្ទះសារ)" ។ នាងនោះ ជាមនុស្សស្រីប្រណែន យកខ្ទះរងើកភ្លើងជះស្រីរួមប្ដី ។ បានឮថា នាងរបាំម្នាក់របស់ព្រះរាជាព្រះអង្គនោះ ដាក់ខ្ទះ រងើកភ្លើងទុកក្នុងទីជិត ជូតទឹកអំពីខ្លួននិងអប់ដោយបាតដៃ ។ ព្រះរាជាទ្រង់សន្ទនានឹងនាងរបាំនោះ និងទ្រង់សម្ដែងអាការប្រោសប្រាណច្រើនពេក ។ ព្រះអគ្គមហេសី ទ្រង់អត់ទ្រាំទតមើលហេតុការណ៍នោះ មិនកម្រើក ទ្រង់ប្រណែន, កាលព្រះរាជាស្ដេចចេញទៅមិនយូរប៉ុន្មាន ក៏ទ្រង់ចាប់ខ្ទះរងើកភ្លើងនោះ ចាក់រងើកភ្លើងស្រោចខាងលើនាងរបាំនោះ ។ ព្រះនាងធ្វើកម្មនោះហើយកើតក្នុងបេតលោក ដើម្បីសោយវិបាក ដូច្នោះនុ៎ះឯង ។

## ១៦_រឿងចោរឃាតប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញអសីសកពន្ធប្រេត កំពុងអណ្តែតទៅលើអាកាស ប្រេតនោះមានភ្នែកនិងមុខនៅត្រង់ទ្រូង ពួកត្មាត ក្អែក អោត ដេញតាមឆាប ចោមចឹកចោះ កើចជញ្ជែង នូវប្រេតនោះ ប្រេតនោះ ក៏ចេះតែស្រែកថ្ងូរ ។

ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (ពីដើម) ឈ្មោះហារិកៈ ជាអ្នកពិឃាតចោរ ក្នុងក្រុងរាជគ្រឹះនេះឯង ។

<u>អដ្ឋកថា</u> ពេជ្ឈឃាតចោរនោះ កាត់ក្បាលពួកចោរអស់កាលយូរមកហើយ តាមពាក្យបង្គាប់របស់ព្រះរាជា កាលកើតក្នុងបេតលោក ទើបបានកើតជាប្រេតមានរាងកាយអត់ក្បាល ។

## ១៧_រឿងភិក្ខុប្រេតជាដើម

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញភិក្ខុកំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់ភិក្ខុនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្តពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ

រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនុ៎ះ (ពីដើម) ជាភិក្ខុលាមក ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។ ចប់សូត្រទី ៧ ។

ខ្ញុំបានឃើញភិក្ខុនីកំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់ភិក្ខុនីនោះក្តី មានភ្លើងឆេះ ។បេ។ ជាភិក្ខុនីលាមក ។ ចប់សូត្រទី ៨ ។

ខ្ញុំបានឃើញសិក្ខមានា កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សិក្ខមានានោះក្តី មានភ្លើងឆេះ ។បេ។ ជាសិក្ខមានាលាមក ។ ចប់សូត្រទី ៩ ។

ខ្ញុំបានឃើញសាមណេរ កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សាមណេរនោះក្តី មានភ្លើងឆេះ ។បេ។ ជាសាមណេរលាមក ។ ចប់សូត្រទី ១០ ។

អដ្ឋកថា : បទថា **បាបភិក្ខុ** គឺជាភិក្ខុលាមក ។

បានឮថា ភិក្ខុនោះបរិភោគបច្ច័យ ៤ ដែលគេប្រគេនដោយសទ្ធារបស់គេ ជាអ្នកមិនសង្រួមផ្លូវកាយទ្វារ និងវចីទ្វារ មានអាជីវៈដែលទម្លាយហើយ ត្រាច់លេងសប្បាយ រីករាយតាមពេញចិត្ត ។ ខាងក្រោយត្រូវភ្លើងឆេះនៅក្នុងនរក រហូត

ដល់អស់មួយពុទ្ធន្តរ កាលកើតក្នុងបេតលោក ក៏កើតដោយអត្តភាពដូចនឹងភិក្ខុនុ៎ះឯង ។ សូម្បីក្នុងរឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរ រឿងសាមណេរីប្រេត ក៏មានសេចក្តីវិនិច្ឆ័យយ៉ាងនេះដែរ ។

## ១៨ រឿងសាមណេរីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញសាមណេរី កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សាមណេរីនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្តពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ សាមណេរីនោះក៏ចេះតែស្រែកថ្ងូរ ។ ម្នាលអាវុសោ ខ្ញុំមានសេចក្តីត្រិះរិះដូច្នេះថា ឱអស្ចារ្យណាស់ហ្ន៎ ឱប្លែកណាស់ហ្ន៎ ឃើអើ សត្វបែបនេះនឹងមានខ្លះដែរ យក្សបែបនេះនឹងមានខ្លះដែរ ការត្រឡប់បានអត្តភាពបែបនេះ នឹងមានខ្លះដែរតើ ។

គ្រានោះ ព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវកមានចក្ខុកើតពិតហើយ ម្នាល

ភិក្ខុទាំងឡាយ ពួកសាវកមានញាណកើតពិតហើយ ដ្បិតថា សាវកនឹងដឹង ឬនឹងឃើញនូវសាមណេរីបែបនេះ នឹងធ្វើជាសាក្សី (ដល់តថាគតបាន) ។

ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះ តថាគតធ្លាប់បានឃើញមកពីមុនដែរ ។ តែថា តថាគតមិនទាន់បានព្យាករ បើតថាគតព្យាករហេតុនោះទៅ ជនទាំងឡាយដទៃមិនជឿតថាគត ពួកជនណាមិនជឿតថាគត ហេតុដែលមិនជឿនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ជនទាំងនោះអស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះ (ពីដើម) ជាសាមណេរីលាមកក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ដោយវិបាកនៃកម្មនោះ សាមណេរីនោះ ក៏ឆេះនៅក្នុងនរក អស់ឆ្នាំទាំងឡាយដ៏ច្រើន អស់រយឆ្នាំដ៏ច្រើន អស់ពាន់ឆ្នាំដ៏ច្រើន អស់សែនឆ្នាំដ៏ច្រើន ដោយសេសសល់វិបាកនៃកម្មនោះឯង ទើបត្រឡប់បាននូវអត្តភាពបែបនេះ ។

(បាកវិនយបិដក និងសុត្តន្តបិដក លេខ១៣២ ទំព័រ២៥៣)

។ ចប់ ។

# III. អត្ថបទកំណាព្យ

## ១_ទេវទូត

១-ទេវទូតទាំងឡាយប្រាំប្រការ ដែលព្រះសាស្តាទ្រង់សម្តែង
រឿងនេះមានពិតយ៉ាងជាក់ស្តែង ហេតុដូច្នេះឯងយើងត្រូវដឹង ។
២-គឺត្រូវតែយល់ត្រូវសិក្សា គិតពិចារណាហើយត្រូវប្រឹង
ត្រូវចេះប្រៀបធៀបពេលសម្លឹង នោះអ្នកនឹងដឹងរូបកាយា ។
៣-ទី១ ក៏គឺទារកខ្ចី មិនទាន់ដឹងក្តីអ្វីឡើយណា
មិនអាចក្រោករួចដោយអាត្មា គួរពិចារណាដោយឧបាយ ។
៤-ទី២ ជរា ចាស់គ្រាំគ្រា សោយទុក្ខវេទនាតាមផ្លូវកាយ
ខ្នងកោងញាប់ញ័រសៃនខ្វល់ខ្វាយ រស់មិនសប្បាយខ្លួនសៅហ្មង ។
៥-ទី៣ ព្យាធិ រោគឈឺចាប់ លំបាកយ៉ាកយ៉ាប់ពេកកន្លង
សព្វសរីរៈនោះតែម្តង មិនអាចអ្នកផងជួយរក្សា ។
៦-ទី៤ កម្មករណ៍ ៣២ នេះតែងញាំញីដល់ជនណា
ប្រព្រឹត្តអាក្រក់ត្រូវរាជការ ដាក់ទោសប្រហារទៅតាមកម្ម ។

៧-ទី៥ អ្នកស្លាប់អស់មួយថ្ងៃ    អស់ពីរបីថ្ងៃ បែកខន្ធប្រាំ

កាយនេះហើមប៉ោងត្រូវប្រេះស្រាំ វិនាសតាមកម្មគួរនឿយណាយ ។

៨-ទាំងនេះបើអ្នកចេះសម្លឹង    អ្នកនឹងបានដឹងដោយឧបាយ

ខន្ធប្រាំមិនទៀងតែងប្រែក្លាយ  មានភ័យអន្តរាយច្រើនប្រការ ។

៩-រូបគេយ៉ាងណាយើងយ៉ាងហ្នឹង   គប្បីរំពឹងដោយបញ្ញា

កាត់អវិជ្ជានិងតណ្ហា    តាំងក្នុងសម្មាបដិបត្តិ ។

១០-ប្រព្រឹត្តទានសីលភាវនា    ព្យាយាមម្នីម្នាយ៉ាងម៉ឺងម៉ាត់

សិក្សាឱ្យយល់បរិយត្តិ    ហើយបដិបត្តិនឹងផុតទុក្ខ ។

និគ្រោធវ័ន ថ្ងៃ ០៥រោច ខែកត្តិក ព.ស.២៥៥៦

ភិក្ខុ សុវណ្ណជោតោ ភ.ស.វ.

# ២-ឃ្លាតទុក្ខជួបសុខ

១-មេឃខ្មៅងងឹត ហាក់ប្រាកដពិត ថានឹងធ្លាក់ភ្លៀង
តែទោះយ៉ាងណា ធម្មជាតិមិនទៀង អាចប្រែជាឃ្មៀង
ទៅជាស្រទន់ ។

២-វិវៀងជីវិត អ្នកមានគំនិត បញ្ញាច្បងច្បាស់
មានចិត្តអំណត់ ព្យាយាមឱ្យណាស់ អ្នកនឹងត្រចាស់
ព្រោះប្រព្រឹត្តល្អ ។

៣-ចម្រើនយ៉ាងណា អ្នកគួរពិចារណ៍ គំនិតបវរ
អ្វីៗមិនទៀង កុំឃើញតែល្អ ទ្រុឌទ្រោមបន្ត
ជានិច្ចរាល់ថ្ងៃ ។

៤-គួរមានបញ្ញា ស្មារតីភ្លឺថ្លា ត្រិះរិះកែខៃ
សិក្សាប្រព្រឹត្ត នូវព្រះធម៌ថ្លៃ ពិតមានតម្លៃ
ឃ្លាតទុក្ខជួបសុខ ។

ដោយភិក្ខុ សុវណ្ណជោតោ ភ.ស.វ.

# ៣~ត្រូវប្រព្រឹត្តធម៌

១-ផ្លែមេឃស្រទ្បះ ហាក់ប្រាកដណាស់ ថាមិនធ្លាក់ភ្លៀង
តែទោះយ៉ាងណា ធម្មជាតិមិនទៀង អាចប្រែជាឃ្លៀង
ទៅជាភ្លៀងបាន ។

២-វីរឿងជីវិត មិនប្រាកដពិត ថានៅតែថ្កាន
ព្រោះរឿងលាភយស ឬក្ដីសុខសាន្ដ ព្រះសម្ពុទ្ធបាន
ត្រាស់ថាមិនទៀង ។

៣-បើអ្នកប្រមាទ មិនប្រឹងសង្វាត នោះអ្នកនឹងឃ្លៀង
ឃ្លាតចាកលាភយស ចិត្តក៏លំអៀង នេះហៅមិនទៀង
នៃធម៌ក្នុងលោក ។

៤-ហេតុដូច្នេះហើយ អ្នកកុំតោះតើយ បើចង់មានជោគ
ចង់បានក្ដីសុខ មានភ័ព្វមានភោគ ចង់ឆ្លងផុតលោក
ត្រូវប្រព្រឹត្តធម៌ ។

ដោយភិក្ខុ សុវណ្ណជោតោ ភ.ស.វ.